សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYAL UNIVERSITY OF LAW AND ECONOMIC

# សារណាបញ្ចប់ការសិក្សា

# អន្តការអេយ្យការ

តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ជា គីមសៀ** សាស្ត្រាចារ្យណែនាំ

**ភិន្ទ ច័ន្ទរិណែត** លោក **ហោ សុត័ណ្ណ**

ថ្នាក់បរិញ្ញាប័ត្រ នីតិសាស្ត្រ ឆ្នាំសិក្សា ២០១៣

ជំនាន់ទី ១៧ ឆ្នាំសរសេរសារណា ២០១៧

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ**ជា គីមសៀ** និង **តិន ចន្ទ័រីណែត** សូមក្រាបថ្វាយបង្គំដល់ព្រះមហាក្សត្រដែលជាម្លប់ដល់កូនចៅ ។

កូនសូមគោរពថ្លែងអំណាគុណ និង សំដែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូន ចំពោះ លោក ឪពុក អ្នកម្តាយដែលលោកមានគុណទាំងពីរបានផ្តល់កំណើតដល់រូបយើងខ្ញុំហើយលោកបានចំណាយពេលវេលា និងខិតខំបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្តីដោយមិនគិតពីភាពនឿយហត់ ដោយលោកទាំងពីរ បានជួយទំនុកបម្រុង ផ្គត់ផ្គង់ទាំងផ្នែកស្មារតី និងសម្ភារៈ ដល់ការសិក្សារបស់ពួកយើងខ្ញុំ ដោយលោកបានអប់រំប្រៀនប្រដៅបន្ទាប់ពីលោកគ្រូ អ្នកគ្រូ នៅសាលា រហូតដល់បញ្ចប់ការសិក្សា ដោយសារលោកមានគុណទាំងពីរទើបយើងខ្ញុំទទួលបានលិទ្ធផលល្អគួរជាទីមោទនៈភាពដូចថ្ងៃនេះ ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ថ្នាក់ដឹកនាំសាកលវិទ្យាល័យព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលដ៏មានតម្លៃ ក្នុងការអប់រំបណ្តុះបណ្តាលយ៉ាងយកចិត្តទុកដាក់ និងស្វះស្វែងរិះរកឯកសារណាដែលថ្មីល្អៗដើម្បីចែករំលែកចំណេះដឹងទាំងនោះដល់យើងខ្ញុំ និងតែងតែអប់រំយើងខ្ញុំឲ្យប្រព្រឹត្តអំពើរល្អហើយលើកទឹកចិត្តយើងខ្ញុំនៅក្នុងការសិក្សា ។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកសាស្ត្រាចារ្យ **ហោ សុភ័ណ្ឌា** ដែលបានខិតខំជួយណែនាំ និងផ្តល់គំនិតជាច្រើនដែលមានសារៈសំខាន់ក្នុងការរៀបចំសៀវភៅនេះឡើងប្រកបដោយភាពជោគជ័យ ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យជូនចំពោះអ្នកមានគុណទាំងពីរ មិត្តភក្តិ ថ្នាក់ដឹកនាំនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំង លោក លោកស្រី ដែលជាសាស្ត្រាចារ្យទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាផ្នែកនីតិសាស្រ្ត អស់រយៈពេល៤ឆ្នាំ យើងខ្ញុំពិតជាមានភាពរីករាយជាខ្លាំងដោយមានកិត្តិយសបានចូលរួមចងក្រង សរសេរសារណាបញ្ចប់ការសិក្សានេះ ដោយការសិក្សារបស់យើងមានការទាក់ទងជាមួយផ្នែកច្បាប់ ដូចនេះយើងខ្ញុំបានជ្រើសរើសយកប្រធានបទស្តីពី "អង្គការអយ្យការ" ក្នុងគោលបំណងបង្ហាញអំពីអំណាចនឹងការប្រព្រឹត្តទៅរបស់ព្រះរាជអាជ្ញានៅក្នុងសង្គមខ្មែរក្នុងការការពារ និងស្វែងរកយុត្តិធម៌ជូនប្រជាជន ។

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដែលមាននៅអមគ្រប់សាលាជម្រះក្តី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាអ្នកតំណាងអោយសង្គម និងជាអ្នកតំណាងការពារផលប្រយោជន៍សារធារណៈ និងធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌទៅលើជនដែលបានប្រព្រឹត្តបទល្មើស ។ ហើយស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដែលមានសារៈសំខាន់ណាស់នៅក្នុងការដំណើរការរឿងក្តីព្រហ្មទណ្ឌ ព្រោះថា អំពើរគំរាមកំហែងតែងតែកើតមានឡើងនៅគ្រប់សង្គមទាំងអស់លើពិភពលោកយើងនេះ និងជះឥទ្ធិពលដល់សណ្តាប់ធ្នាប់សាធារណៈ ដែលធ្វើឲ្យរាំខានដល់ការអភិវឌ្ឍន៍ប្រទេស ។

យើងខ្ញុំសង្ឃឹមថា សារណាដែលយើងខ្ញុំបានសរសេរឡើងនេះនឹងក្លាយជា ឯកាសារផ្នែកច្បាប់មួយដែលមានសារៈប្រយោជន៍ ដល់និស្សិតជំនាន់ក្រោយៗទៀត ក្នុងការពង្រឹងនឹងលើកស្ទួយវិស័យផ្នែកច្បាប់ឲ្យកាន់តែរឹងមាំ ។ ជាមួយសារណាមួយច្បាប់ដែលយើងបានរៀបរៀងឡើងនេះ យើងខ្ញុំសង្ឃឹមថា វាជាឯកសារមួយដែលជាជំនួយអាចជួយពង្រឹងដល់មុខវិជ្ជា ទាំងឡាយណាដែលទាក់ទងនឹងផ្នែកច្បាប់ចំពោះនិស្សិតដែលបានសិក្សាផ្នែកនេះ ហើយក៏ដូចជាសិស្សនិស្សិតដែលសិក្សាផ្នែក សេដ្ឋកិច្ចផងដែរ ។

យ៉ាងណាមិញសារណាមួយក្បាលនេះ បានលេចចេញជារូបរាងហើយក៏ដោយ ក៏យើងខ្ញុំយល់ថានៅមានកង្វះខ្វះខាតមួយចំនួនដែរ ហើយយើងខ្ញុំរីករាយ និងស្វាគមន៍រាល់ការរិះគន់កែតំរូវរាល់ចំណុចខ្វះខាតទាំងនោះដែលយើងខ្ញុំមានក្នុងការចងក្រងសៀវភៅមួយនេះ ។ ហើយយើងខ្ញុំក៏សូមអរគុណផងដែរ រាល់ការរិះគន់ កែតំរូវ ក្នុងគោលបំណងស្ថាបនាដល់យើងខ្ញុំ នូវចំណុចខ្វះខាតទាំងនោះ ។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក និងលោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់នូវពទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណះ សុខះ ពលះ កុំបីឃ្លាងឃ្លាត ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ......... **១**

**<u>ជំពូកទី ១</u> អង្គការអយ្យការ**

**ផ្នែកទី ១៖ ឋានានុក្រមនៃអង្គការអយ្យការ** ......... **៣**

កឋាភាគទី ១៖ អង្គការអយ្យការអមសាលាកំពូល ......... **៤**

កឋាភាគទី ២៖ អង្គការអយ្យការអមសាលាឧទ្ធរណ៍ ......... **៥**

កឋាភាគទី ៣៖ អង្គការអយ្យការអមសាលាដំបូង ......... **៥**

**ផ្នែកទី ២៖ គោលការណ៍សំខាន់ៗនៃអង្គការអយ្យការ** ......... **៥**

**ផ្នែកទី ៣៖ ការជ្រើសរើសព្រះរាជអាជ្ញា** ......... **៧**

កឋាភាគទី ១៖ ការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ......... **៩**

**<u>ជំពូកទី ២</u> អង្គការអយ្យការនៅអមសាលាដំបូង**

**ផ្នែកទី ១៖ តួនាទី និងអំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង** ......... **១២**

កឋាភាគទី ១៖ អំណាចរបស់ព្រះរាជអាជ្ញាក្នុងការធ្វើបណ្តឹងអាជ្ញា ......... **១៣**

កឋាភាគទី ២៖ អំណាចក្នុងការស៊ើបអង្កេតបឋម ......... **១៣**

កឋាភាគទី ៣៖ អំណាចក្នុងការឃាត់ខ្លួន ......... **១៣**

កឋាភាគទី ៤៖ អំណាចក្នុងការបញ្ជូនខ្លួន ......... **១៥**

កឋាភាគទី ៥៖ អំណាចក្នុងការឆែកឆេរ ......... **១៥**

**ផ្នែកទី ២៖ ជម្រើសនៃការចោទប្រកាន់** ......... **១៦**

កឋាភាគទី ១៖ ការតម្កល់រឿងទុកឥតចាត់ការ ......... **១៦**

កបាភាគទី ២៖ ការចោទប្រកាន់ ............ ១៧

កបាភាគទី ៣៖ ការបើកការស៊ើបសួរ ............ ១៧

កបាភាគទី ៤៖ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ............ ១៨

កបាភាគទី ៥៖ ការបង្ហាញខ្លួន ............ ២០

**ផ្នែកទី ៣៖ តួនាទីរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ............ ២២**

កបាភាគទី ១៖

តួនាទីរបស់អគ្គព្រះរាជអាជ្ញាចំពោះសេចក្ដីសម្រេចរបស់ចៅក្រម ............ ២៣

១.១-រយៈពេលធ្វើបណ្ដឹងឧទ្ធរណ៍ ............ ២៤

១.២-អានុភាពនៃបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា ............ ២៥

**ផ្នែកទី ៤៖ តួនាទីរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ............ ២៦**

**ជំពូកទី ៣ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ព្រះរាជអាជ្ញា**

**ផ្នែកទី ១៖ ការតែងតាំង ផ្លាស់ប្ដូរ ផ្អាច់ពីមុខងារ ដាក់ឲ្យនៅក្រៅក្របខណ្ឌ ដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចោលរបស់ព្រះរាជអាជ្ញា ............ ៣០**

កបាភាគទី ១៖ ការសុំផ្អាច់ពីមុខងារ ............ ៣១

កបាភាគទី ២៖ ការសុំនៅក្រៅក្របខណ្ឌ ............ ៣១

កបាភាគទី ៣៖ ការស្នើសុំនៅទំនេរគ្មានបៀវត្ស ............ ៣២

**ផ្នែកទី ២៖ ទណ្ឌកម្មវិន័យ និងការលុបឈ្មោះរបស់ព្រះរាជអាជ្ញា ............ ៣៣**

**ផ្នែកទី ៣៖ ការចោទប្រកាន់តាមផ្លូវតុលាការ ............ ៣៤**

**ផ្នែកទី ៤៖ ការចូលនិវត្តន៍របស់ព្រះរាជអាជ្ញា ............ ៣៦**

**សេចក្ដីសន្និដ្ឋាន ............ ៤០**

## ឯកសារយោង

## ឧបសម្ព័ន្ធ

# សេចក្ដីផ្ដើម

នៅក្នុងរដ្ឋនីមួយៗនៅលើពិភពលោកនេះសុទ្ធតែមានរចនាសម្ព័ន្ធ និងការអនុវត្តច្បាប់ អំណាចនានានៅក្នុងប្រទេសរបស់ខ្លួនប្រកបដោយឥទ្ធិពលដើម្បីឆ្ពោះទៅកាន់ភាពជោគជ័យទៅលើដំណើរការនៅក្នុងរដ្ឋរបស់ខ្លួន ។ ក៏ដូចគ្នាដែរនៅក្នុងប្រទេសកម្ពុជាយើងក៏មានចែកចេញជា ស្ថាប័នផ្សេងៗជាច្រើន ដែលស្ថាប័នទាំងនោះមានតួនាទី និងភារកិច្ចផ្សេងៗគ្នា ក្នុងការធ្វើឲ្យប្រទេសកម្ពុជាមានដំណើរការរលូនទៅមុខ។ ក៏ដូចជាស្ថាប័នអយ្យការដែលនៅអមតុលាការ នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនេះផងដែរ។ ស្ថាប័នឬអង្គការអយ្យការអមតុលាការជម្រះក្ដីកម្ពុជា និងត្រូវលើកយកមកធ្វើការបកស្រាយយ៉ាងក្បោះក្បាយ និងធ្វើការរៀបចំតាក់តែងឡើង ដើម្បីធ្វើឲ្យមានភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវរបស់អ្នកអានគ្រប់រូបផងដែរ។

នៅក្នុងសារណាបញ្ចប់ការសិក្សាដែលផ្ដោតទៅលើប្រធានបទ អង្គការអយ្យការ នេះនឹងធ្វើការបកស្រាយ និងការប្រមូលឯកសារដោយការរួមបញ្ចូលគ្នាទាំងអស់ទៅលើឯកសារណាដែល ទាក់ទងទៅនឹងអង្គការអយ្យការ ដែលនៅក្នុងសារណាបញ្ចប់ការសិក្សានេះ និងធ្វើការពន្យល់ និងលើកឡើងនូវចំណុចជាច្រើនដែលទាក់ទងទៅនឹង ឋានានុក្រមនៃអយ្យការ និងគោលការណ៍សំខាន់ៗនៃអង្គការអយ្យការផងដែរ។ មិនតែប៉ុណ្ណោះ ពួកយើងក៏បានលើកឡើងនូវចំណុចដែលទាក់ទងទៅនឹងការជ្រើសរើសព្រះរាជអាជ្ញា និងការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញានៅក្រោយពេលបញ្ចប់ការចុះកម្មសិក្សាពេញលេញ។ ជាពិសេសជាងនេះទៅទៀតនោះ សារណានេះក៏បានធ្វើការបង្ហាញពីតួនាទី និងអំណាច់របស់ព្រះរាជអាជ្ញា ដែលនៅអមសាលាជម្រះក្ដីទាំងបីជាន់ថ្នាក់ដែលនៅសាលាដំបូងបានបែងចែកជាច្រើនដូចជា អំណាចក្នុងការធ្វើបណ្ដឹងអាជ្ញា អំណាចក្នុងការធ្វើការស៊ើបអង្កេតបឋម អំណាចក្នុងការឃាត់ខ្លួន អំណាចក្នុងការបញ្ជូនខ្លួន និងអំណាចក្នុងការឆែកឆេរ។ ទាក់ទងផងដែរទៅលើអំណាចរបស់ព្រះរាជអាជ្ញាផងដែរដែលមានដូចជាសិទ្ធិក្នុងការតម្កល់រឿងទុកឥតចាត់ការ អំណាចក្នុងការចោទប្រកាន់ ការបើកការស៊ើបសួរ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងការបង្ហាញខ្លួនផងដែរ ក៏ដូចជាអំណាចដ៏ទៃទៀតនៅក្នុងសាលាឧទ្ធរណ៍ និងតំពូលនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនេះ។ បន្តពីនេះទៅទៀត

ពួកយើងក៏បានធ្វើការដាក់បញ្ចូលនូវការតែងតាំង ផ្លាស់ប្តូរ ផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចោលរបស់ព្រះរាជអាជ្ញាផងដែរ។ អ្នកក៏អាចរកឃើញនូវការដាក់ទណ្ឌកម្មវិន័យ និងការលុបឈ្មោះចោលរបស់ព្រះរាជអាជ្ញា ថាតើដោយហេតុដូចម្តេចខ្លះទើបអាចមានការដាក់ទណ្ឌកម្មវិន័យ និងការលុបឈ្មោះចោល ជាពិសេសនោះការចោទប្រកាន់តាមផ្លូវតុលាការទៅលើព្រះរាជអាជ្ញា។ ជាចុងក្រោយអ្នកនឹងស្វែងយល់ទៅលើការចូលនិវត្តន៍របស់ព្រះរាជអាជ្ញា ហើយតើព្រះរាជអាជ្ញាអាចបំពេញការងាររបស់ខ្លួនបានរហូតដល់អាយុប៉ុន្មាន និងថាតើព្រះរាជអាជ្ញាអាចសុំចូលនិវត្តន៍មុនដែរឬនោះទេ? សំនួរទាំងនេះនិងត្រូវបានឆ្លើយនៅក្នុងសារណាបញ្ចប់កាសិក្សានេះ។

# ជំពូកទី ១
# អង្គការអយ្យការ

អង្គការអយ្យការគឺជាអង្គការដ៏សំខាន់មួយដែលនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ចាប់ពីតុលាការជំបូង តុលាការឧទ្ធរណ៍ និងតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា។

អង្គការអយ្យការមានតួនាទីក្នុងការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ ទាំងឡាយណាដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ឬស្ថិតនៅក្រោមឋានានុក្រមនៃអង្គការអយ្យការ។ ហើយអង្គការអយ្យការក៏មានតួនាទីក្នុងការសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់ផងដែរ។ ដែលអង្គការអយ្យការត្រូវធ្វើការធានារ៉ាប់រងនិងផ្តោតសំខាន់ទៅលើការផ្សព្វផ្សាយដីការបង្គាប់ឲ្យចាប់ខ្លួន។ ដើម្បីអោយការបំពេញភារកិច្ចរបស់អង្គការអយ្យការឲ្យមានភាពពេញលេញនោះ ចៅក្រមអយ្យការ មានអំណាចក្នុងការកេណ្ឌកម្លាំងសាធារណៈដោយខ្លួនផ្ទាល់ដើម្បីជាជំនួយ។ ចៅក្រមអយ្យការមានភារកិច្ចក្នុងការបង្ហាញមុខនៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌជាដាច់ខាត។[1]

ចៅក្រមអយ្យការមានៈ

- អគ្គព្រះរាជាអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល។
- អគ្គព្រះរាជាអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការឧទ្ធរណ៍។
- ព្រះរាជាអាជ្ញា និងព្រះរាជអាជ្ញារងអមតុលាការជំបូង។[2]

## ផ្នែកទី ១៖ ឋានានុក្រមនៃអង្គការអយ្យការ

ឋានានុក្រមនៃអង្គការអយ្យការមានជាច្រើនចំណុចដែលបង្ហាញពីឋានានុក្រម និងអំណាចនៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឲ្យបានគ្រប់ជ្រុងជ្រោយ។ ដូចនេះបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានដឹងពីបទល្មើសណាមួយ ខ្លួនអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ជូនទៅក្នុងសំណុំរឿង ដោយប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងទាក់ទងទៅនឹងបទល្មើសនោះ ដើម្បីអគ្គព្រះរាជាអាជ្ញា ឬព្រះរាជាអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណា

---

[1] មាត្រា២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[2] មាត្រា២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

ទៅតាមដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ ប៉ុន្តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌គ្មានសិទ្ធិអំណាចក្នុងការធ្វើអធិបញ្ញាទៅកាន់ អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាឲ្យធ្វើការតម្កល់ទុកឥតចាត់ការទៅលើរឿងក្ដីព្រហ្មទណ្ឌណាមួយបាននោះទេ។[3]

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិអំណាច ទៅលើចៅក្រមអយ្យការទាំងអស់ដែលស្ថិតនៅក្រោមសម្ថកិច្ចដែនដីរបស់ខ្លួន ហើយមានសិទ្ធិក្នុងការធ្វើអធិបញ្ញាឲ្យធ្វើការចោទប្រកាន់ ឬចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាដែលខ្លួនគិតថាគួរ។ ចំណែកឯព្រះរាជអាជ្ញាវិញមានសិទ្ធិអំណាចទៅលើចៅក្រមអយ្យការណាមួយដែលស្ថិតនៅក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន និងមានសិទ្ធិក្នុងការធ្វើអធិបញ្ញាឲ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬធ្វើការចាត់ឲ្យចោទប្រកាន់ ឬធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាទៅតាមអ្វីដែលខ្លួនយល់ឃើញថាជាការគួរ។[4]

ចៅក្រមអយ្យការគ្រប់រូបត្រូវគោរពតាមអធិបញ្ញារបស់ថ្នាក់លើរបស់ខ្លួន យោងទៅតាមឋានានុក្រម ក៏ប៉ុន្តែនៅពេលសវនាការ ចៅក្រមអយ្យការធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរីបានទៅតាមការដែលខ្លួនយល់ឃើញ និងគិតថាសមស្រប ទៅតាមសតិសម្បជ្ជៈរបស់ខ្លួន។ ហើយគ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចធ្វើទៅបានចំពោះចៅក្រមអយ្យការ ដោយសារតែការនិយាយរបស់ខ្លួនដែលបានបញ្ចេញនៅពេលសវនាការនោះឡើយ។ [5]

## កថាភាគទី ១៖ អង្គការអយ្យការអមសាលាកំពូល

អង្គការអយ្យការអមសាលាកំពូលដែលហៅថា មហាអយ្យការមានដូចតទៅ៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជាអាជ្ញា ព្រមទាំងមន្ត្រីរដ្ឋបាល (ក្រឡាបញ្ជី) ខ្លះៗទៀតប្រសិនជាចាំបាច់។[6]

---

[3] មាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[4] *Id.*

[5] មាត្រា៣០ នៃក្រមនីតិវិធិព្រហ្មទណ្ឌ ២០០៧

[6] ស្វរីដា. ដំណើរការរឿងក្ដីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន. បោះពុម្ពលើកទី១, ទ.៣០, ឆ្នាំ ២០១១

### កថាភាគទី ២៖ អង្គការអយ្យការអមសាលាឧទ្ធរណ៍

អង្គការអយ្យការអមសាលាឧទ្ធរណ៍ដែលហៅថា មហាអយ្យការមានដូចតទៅ៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជាអាជ្ញា ព្រមទាំងមន្ត្រីរដ្ឋបាល (ក្រឡាបញ្ជី) ខ្លះៗទៀតប្រសិនជាចាំបាច់។[7]

### កថាភាគទី ៣៖ អង្គការអយ្យការអមសាលាដំបូង

អង្គការអយ្យការអមសាលាដំបូងដែលហៅថា អយ្យការមានដូចតទៅ៖

- ព្រះរាជអាជ្ញា និង
- ព្រះរាជអាជ្ញា ព្រមទាំងមន្ត្រីរដ្ឋបាល (ក្រឡាបញ្ជី) ខ្លះៗទៀតប្រសិនជាចាំបាច់។

អង្គការអយ្យការតែមួយគត់ដែលមានអំណាចក្នុងការធ្វើបណ្ដឹងអាជ្ញា ហើយព្រះរាជអាជ្ញាជាអ្នកទទួលបន្ទុកក្នុងការស្វែងរកបទល្មើសព្រហ្មទណ្ឌដែលកើតមានឡើង ហើយធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌនោះ។ ជាពិសេសជាងនេះទៅទៀត ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការសុំឲ្យអនុវត្តច្បាប់ចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។

## ផ្នែកទី ២៖ គោលការណ៍សំខាន់ៗនៃអង្គការអយ្យការ

គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការមានដូចតទៅ៖

អង្គការអយ្យការគឺជាអង្គឯកភាពមួយដែលគ្រប់ព្រះរាជាអាជ្ញាទាំងអស់ មានតួនាទីក្នុងការមើលទៅលើការខុសត្រូវទៅលើបញ្ហាទាំងអស់ដែលស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យរបស់ខ្លួនទៅតាមឋានានុក្រមរបស់ខ្លួននោះ។ ម៉្យាងវិញទៀតនោះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌គឺជានាយកឋាននុក្រមនៃអង្គការអយ្យការ ដូចនេះមានន័យថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានសិទ្ធិក្នុងការធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅកាន់អង្គការ

[7] *Id.* p30

អយ្យការគ្រប់ជាន់ថ្នាក់ទាំងអស់។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចនេះ ។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលគឺជានាយឋានុក្រមនៃមហាអយ្យការ អមតុលាការកំពូល ចំណែកឯព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូលវិញគឺស្ថិតនៅក្រោមការដឹកនាំ និងទំនួលខុសត្រូវជារួមមួយរបស់អគ្គព្រះរាជាអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួននោះផងដែរ ។

អគ្គព្រះរាជអាជ្ញាអមតុលាការឧទ្ធរណ៍គឺជានាយឋានុក្រមនៃមហាអយ្យការអមតុលាការឧទ្ធរណ៍ ចំណែកឯព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការឧទ្ធរណ៍វិញគឺស្ថិតនៅក្រោមការដឹកនាំ និងទំនួលខុសត្រូវជារួមមួយរបស់អគ្គព្រះរាជាអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួននោះ ។

ព្រះរាជអាជ្ញាអមតុលាការដំបូងជានាយឋានុក្រមនៃអយ្យការ អមតុលាការដំបូង ចំណែកឯ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូងវិញគឺស្ថិតនៅក្រោមការដឹកនាំ និងទំនួលខុសត្រូវជារួមមួយរបស់ ព្រះរាជាអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួននោះផងដែរ ។

អង្គការអយ្យការគឺជាអង្គអវិភាគ មានន័យថា ព្រះរាជអាជ្ញាទាំងអស់ ត្រូវបំពេញមុខងារនៅក្នុង អង្គការអយ្យការអមសាលាជម្រះក្តីទាំងអស់នោះ នៅតែមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា ដូច្នេះព្រះរាជអាជ្ញាទាំងអស់មានសិទ្ធិក្នុងការចូលជំនួសគ្នាទៅវិញទៅមកបាន។ តំណាងអង្គការអយ្យការច្រើនរូប អាចមានសិទ្ធិបន្តការងារ តពីគ្នាបាននៅក្នុងសំណុំរឿងតែមួយនោះទៅតាមការចាត់តាំងរបស់នាយឋានានុក្រមរបស់ខ្លួន ។

អង្គការអយ្យការ ទទួលបានឈ្មោះថាជាអង្គការមួយដែលដើរអមសាលាជម្រះក្តីទាំងបីជាន់ថ្នាក់នោះមែន ក៏ប៉ុន្តែ អង្គការអយ្យការដើរតួរជាអង្គឯករាជ្យមួយ ហើយមិនស្ថិតនៅក្រោមអំណាច ឬឥទ្ធិពលរបស់សាលាជម្រះក្តីដែលខ្លួនអមនោះទេ ដូចនេះ សាលាជម្រះក្តីទាំងបីជាន់ថ្នាក់ពុំមានអំណាចក្នុងការត្រួតពិនិត្យកិច្ចការងាររបស់ព្រះរាជអាជ្ញានោះទេ។ ដូចនេះ ទោះបីនៅក្នុងករណីដែលព្រះរាជអាជ្ញាបានប្រព្រឹត្តកំហុសឆ្គងណាមួយនៅក្នុងពេលបំពេញមុខងា និងភារកិច្ចរបស់ខ្លួននោះ សាលាជម្រះក្តីក៏គ្មានសិទ្ធិក្នុងការចុះក្នុងសេច

ក្ដីសម្រេចរបស់ខ្លួនទាក់ទងទៅនឹងកំហុស ដែលព្រះរាជអាជ្ញាបានប្រព្រឹត្តនៅក្នុងនោះក្នុងគោលបំណងស្ដីបន្ទោសចំពោះព្រះរាជអាជ្ញានោះដែរ។ ដើម្បីធ្វើការបង្ហាញកំហុសឆ្គងរបស់ព្រះរាជអាជ្ញានោះ សាលាជម្រះក្ដីអាចធ្វើការលើកសំណើរទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញានោះបាន។

ជារៀងរាល់ឆ្នាំ ព្រះរាជអាជ្ញាអមសាលាដំបូង ត្រូវធ្វើរបាយការណ៍អំពីបទល្មើស និងសកម្មភាពនៃការងាររបស់ខ្លួនជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងផ្ញើឯកសារចម្លងមួយជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចដែនដី។ ក៏ដូចគ្នាដែរទៅលើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយខ្លួនត្រូវ ធ្វើរបាយការណ៍អំពីបទល្មើស និងសកម្មភាពនៃការងាររបស់ខ្លួន រួមជាមួយនិងសកម្មភាពការងាររបស់អយ្យការអមសាលាដំបូងទាំងអស់នៅក្នុងសមត្ថិកិច្ចដែនដីរបស់ខ្លួនជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងផ្ញើ ឯកសារចម្លងមួយជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ ចំណែកឯ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ក៏ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំនេះផងដែរ ដែលទាក់ទងទៅលើសកម្មភាពការងាររបស់មហាអយ្យការអមតុលាការកំពូល ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ព្រះរាជអាជ្ញាទាំងឡាយត្រូវអនុវត្តមុខងាររបស់ខ្លួនដោយស្មោះត្រង់ និងឈរលើគោលការណ៍គោរពច្បាប់ដោយមិនទទួល ការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់មាត់ ឬដោយប្រយោល ពីភាគី ឬបុគ្គលណាមួយឡើយក្រៅពីបញ្ជារបស់នាយឋានានុក្រមរបស់ខ្លួន និងអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ឋានន្តរស័ក្តិ និងថ្នាក់របស់ក្របខណ្ឌព្រះរាជអាជ្ញាមាន ៣ ដូចជា ឧត្តមព្រះរាជអាជ្ញា វរៈព្រះរាជអាជ្ញា និងអនុព្រះរាជអាជ្ញាដែលថ្នាក់ទាំងបីនេះត្រូវកំណត់ដោយព្រះរាជក្រឹត្យ។[8]

## ផ្នែកទី ៣៖ ការជ្រើសរើសព្រះរាជអាជ្ញា

ការជ្រើសរើសព្រះរាជអាជ្ញាត្រូវបានធ្វើឡើងតាមការប្រឡងជ្រើសរើសជាសិស្សព្រះរាជអាជ្ញា ប៉ុន្តែ បុគ្គលនោះត្រូវមានលក្ខណសម្បត្តិដូចតទៅ៖

- ត្រូវមានសញ្ជាតិជាខ្មែរពីកំណើត

[8] មាត្រា ៧៥-៧៧, ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ ២០១៤

- ចំពោះបេក្ខជនជានិស្សិត ត្រូវមានអាយុ ៣៥ ( សាមសិបប្រាំ ) ឆ្នាំឡើងទៅ ចំណែកបេក្ខជនជាមន្ត្រីរាជការ ត្រូវមានអាយុ ៤០ ( សែសិប ) ឆ្នាំឡើងទៅគិតមកដល់ថ្ងៃប្រឡង
- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ
- មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។

ការជ្រើសរើសនេះអាចធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងពីក្នុងចំណោមៈ

- មន្ត្រីរាជការ និងក្រឡាបញ្ជី ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងទទួលបានបទពិសោធន៍ក្នុងវិស័យច្បាប់ ឬយុត្តិធម៌យ៉ាងតិចនោះ ៥ ( ប្រាំ ) ឆ្នាំ និងត្រូវមានអាយុមិនលើសពី៤៥ ( សែសិបប្រាំ ) ឆ្នាំគិតមកដល់ថ្ងៃប្រឡង។
- មេធាវីដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងបានបំពេញវិជ្ជាជីវៈរបស់ខ្លួនយ៉ាងតិច ៥ ( ប្រាំ ) ឆ្នាំ អាចចុះឈ្មោះចូលរួមប្រឡងប្រជែងតាមបញ្ញត្តិខាងលើនេះបានដូចគ្នាប្រសិនបើមេធាវីរូបនោះមានអាយុមិនលើសពី ៤៥ ( សែសិបប្រាំ ) ឆ្នាំ គិតមកដល់ថ្ងៃប្រឡងផងដែរ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងធ្វើការពិគ្រោះយោបល់ជាមួយនឹងសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទៅលើការកំណត់ចំនួន នៃការជ្រើសរើសសិស្សព្រះរាជអាជ្ញានេះ ហើយនិងធ្វើការប្រកាសដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បើសិនជាទទួលការយល់ព្រមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមហើយនោះ។ បន្ទាប់មក រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងរៀបចំការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ទៅលើបេក្ខជនទាំងឡាយណាដែលបានប្រឡងជាប់ចូលជាសិស្សព្រះរាជអាជ្ញាដែលការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្ដុះបណ្ដាលវិជ្ជាជីវៈនេះនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏ត្រូវធ្វើការកំណត់ទៅលើបែបបទ នីតិវិធី កាលបរិច្ឆេទ និងទីកន្លែង ព្រមទាំងគណៈមេប្រយោគនៃការប្រឡងប្រជែងជ្រើសរើសសិស្សព្រះរាជអាជ្ញានេះផងដែរ។[9]

[9] មាត្រា ៨២, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ ២០១៤

## កថាភាគទី ១៖ ការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជ-អាជ្ញា

បន្ទាប់ពីសិស្សព្រះរាជអាជ្ញាបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈនោះដោយជោគជ័យហើយ សិស្សព្រះរាជអាជ្ញាទាំងនោះ នឹងត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ទៅជាព្រះរាជអាជ្ញាកម្មសិក្សា ក្នុងឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ ដូចនេះ ព្រះរាជអាជ្ញាកម្មសិក្សាត្រូវធ្វើកម្មសិក្សាក្នុងរយៈពេល ១ ( មួយ ) ឆ្នាំ ដែលគិតពីកាលបរិច្ឆេទនៃការតែងតាំងនោះ។

បន្ទាប់ពីព្រះរាជអាជ្ញាកម្មសិក្សាទទួលបានភាពជោគជ័យក្នុងការបំពេញកម្មសិក្សា រយៈពេល ១ ( មួយ ) ឆ្នាំរបស់ខ្លួនហើយនោះ គាត់នឹងត្រូវបានតែងតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា មានន័យថា គាត់នឹងទទួលបានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ រួចមក ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនិងលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រទៅលើការតែងតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញានេះ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

នៅក្នុងករណីដែលព្រះរាជអាជ្ញាកម្មសិក្សានោះ៖

- ពុំទទួលបានជោគជ័យទៅលើការធ្វើកម្មសិក្សា
- ឬ ត្រូវបានអវត្តមានក្នុងការចុះកម្មសិក្សាអស់រយៈពេលលើសពី ៣០ ( សាមសិប ) ថ្ងៃនោះ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានអំណាចក្នុងការដាក់ឲ្យព្រះរាជអាជ្ញាកម្មសិក្សានោះ ធ្វើកម្មសិក្សាបន្តក្នុងរយៈពេល ១ ( មួយ ) ឆ្នាំបន្ថែមទៀតដែលហៅថា "កម្មសិក្សាបន្ថែម"។ ប៉ុន្តែក្នុងករណីដែលព្រះរាជអាជ្ញាកម្មសិក្សានោះបន្តក្នុងការឈប់លើសពី ៣០ ( សាមសិប ) ថ្ងៃដោយគ្មានការអនុញ្ញាតច្បាប់ ឬធ្វើកម្មសិក្សាដោយពុំបានជោគជ័យជាលើកទីពីរនោះ នឹងត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌព្រះរាជអាជ្ញា។

ព្រះរាជអាជ្ញារូបណាដែលពុំមានកាយសម្បទាគ្រប់គ្រាន់ ឬសុខភាពល្អគ្រប់គ្រាន់ក្នុងការបំពេញការងារនឹងត្រូវបានលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញាបាន នៅគ្រប់ពេលវេលា។ សរុបមកវិញមក ការលុបឈ្មោះចេញ និងការតាំងស៊ប់របស់ព្រះរាជអាជ្ញាកម្ម

សិក្សានេះត្រូវធ្វើឡើងនៅក្នុង អំឡុងពេលមិនលើសពី ៣ ( បី ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់កម្មសិក្សា។

# ជំពូកទី ២

# អង្គការអយ្យការអមតុលាការកម្ពុជា

## ផ្នែកទី ១៖ អង្គការអយ្យការអមតុលាការដំបូង

អង្គការអយ្យការនៅអមតុលាការដំបូងហៅថា អយ្យការដែលរួមមានៈ ព្រះរាជអាជ្ញា និង ព្រះរាជ អាជ្ញារង ។

- **ព្រះរាជអាជ្ញា** ដឹកនាំនិងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ ប៉ុន្តែកាលណាអនុវត្តដីការសម្រេចចាត់ឲ្យស៊ើបជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ។ ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ឲ្យដល់នគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ហើយព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងគ្រប់ការណែនាំដែលមានប្រយោជន៍ដល់បមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ។ ក្នុងករណីចាំបាច់ពិសេសព្រះរាជអាជ្ញាអាចដកសិទ្ធស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រីនេះ និងភ្នាក់ងារនេះ ។ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌ ហើយព្រះរាជអាជ្ញា ក៏អាចចូលរួមក្នុងការស្តាប់ចម្លើយ និងត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ដែលមានចែងនៅក្នុង មាត្រា៣៧ នៃក្រមនីតិវិធិព្រហ្មទណ្ឌ ។
- **ព្រះរាជអាជ្ញារង** ស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើស ។[10]

**ដោយការអនុវត្តសមត្ថកិច្ចដូចះ**

- នៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
- នៃទីលំនៅរបស់ជនដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស
- នៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស

[10] មាត្រា ៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

# ផ្នែកទី ១៖ តួនាទី និងអំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង

## កថាភាគទី ១៖ អំណាចរបស់ព្រះរាជអាជ្ញាក្នុងការធ្វើបណ្តឹងអាជ្ញា

មានតែអង្គការអយ្យការទេដែលមានសិទ្ធិក្នុងការធ្វើបណ្តឹងអាជ្ញា ដែលកិច្ចការនេះត្រូវបានដឹកនាំដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ។[11] កាលណាព្រះរាជអាជ្ញាទទួលបានពាក្យបណ្តឹងបរិហារពីជនណាម្នាក់ ឬពីនគរបាលយុត្តិធម៌ ដែលទាក់ទងនឹងបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមណាមួយ ព្រះរាជអាជ្ញាត្រូវចាត់វិធានការតាមនីតិវិធីនៃច្បាប់ដូចតទៅ:

### ១.១-ការស៊ើបអង្កេតផ្ទាល់របស់ព្រះរាជអាជ្ញា

បន្ទាប់ពីទទួលបានរបាយការណ៍ ពីនគរបាលយុត្តិធម៌ហើយ ព្រះរាជអាជ្ញាត្រូវសាកសួរជនល្មើសនូវពត៌មានដូចតទៅ៖

- អត្តសញ្ញាណរបស់ជនសង្ស័យ ឈ្មោះ អាយុ មុខរបរ ទីលំនៅ ទីកន្លែង និងថ្ងៃ ខែឆ្នាំកំណើត។
- ឈ្មោះ ឪពុក ម្តាយ
- ប្រវត្តិសង្ខេបរបស់ជនសង្ស័យរួមមានបទល្មើសដែលបានប្រព្រឹត្តពីមុន
- បទល្មើសដែលត្រូវបានចោទប្រកាន់
- កាលបរិច្ឆេទ និងទីកន្លែងប្រព្រឹត្តបទល្មើស។

ក្រោយពីបានពិនិត្យមើលសំណុំរឿង ហើយអំពើរដែលគេប្តឹងនោះមិនចូលជាបទល្មើសព្រហ្មទណ្ឌទេ ព្រះរាជអាជ្ញាត្រូវតម្កល់រឿងក្តីនោះទុកមិនចាត់ការដោយចុះ និទ្ទេសលើបណ្តឹងឬ កំណត់ហេតុនោះព្រមទាំងចុះលើបញ្ជីបណ្តឹងផង។

### ១.២-ការតម្កល់រឿងទុកឥតចាត់ការ

មូលហេតុដែលនាំឲ្យ ព្រះរាជអាជ្ញាទុកតម្កល់រឿងឥតចាត់ការរួមមាន៖

- មរណភាពនៃជនល្មើស
- បណ្តឹងអាជ្ញាត្រូវបានផុតរលត់

[11] មាត្រា ១៣១ ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ២០០៨

- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ

ក្រៅពីមូលហេតុខាងលើនេះ ព្រះរាជអាជ្ញាអាចតម្កល់រឿងឥតចាត់ការបានដែរដូចជា៖

- អង្គហេតុនៃរឿងមិនមែនជារឿងព្រហ្មទណ្ឌ
- គោលការណ៍កាលានុវត្តភាព មានន័យថាអង្គហេតុនៃរឿងជារឿង ព្រហ្មទណ្ឌ ប៉ុន្តែវាជាបទល្មើសតូចតាច។

ការតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវធ្វើរលិខិតជូនដំណឹងទៅឲ្យភាគីដើមបណ្តឹង ដើម្បីប្រាប់ពីការឥតចាត់ការនេះដោយនៅក្នុងលិខិតនោះ ព្រះរាជអាជ្ញាត្រូវបញ្ជាក់ដល់អ្នកប្តឹងអំពីសិទ្ធិពេញលេញក្នុងការប្តឹងទៅសាលាឧទ្ធរណ៍ប្រឆាំង និងសេចក្តីសម្រេចមិនចាត់ការនេះ។ ដោយរយៈពេលនៃការប្តឹងតវ៉ា ចំពោះសេចក្តីសម្រេចនេះទៅសាលាឧទ្ធរណ៍មានរយៈពេល ២ខែ គិតពីថ្ងៃទទួលពាក្យបណ្តឹង។

### កឋាភាគទី ២៖ អំណាចក្នុងការស៊ើបអង្កេតបឋម

កាលណាមានអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងព្រះរាជអាជ្ញាមានសិទ្ធិធ្វើការស៊ើបអង្កេតបឋម និងអនុវត្តនូវវិធានការមួយចំនួនដែលច្បាប់ប្រគល់ឲ្យដើម្បីធានាដល់ការស៊ើបអង្កេតដូចជា:

- ការឃាត់ខ្លួនជនសង្ស័យ និងនាំខ្លួន
- ឃាត់ខ្លួនជនទាំងឡាយណាដែលរឹងទទឹង និងបំរាមហាមឃាត់ចេញពីទីកន្លែងកើតហេតុក្នុងរយៈពេល ២៤ ម៉ោង ។
- អាចកេណ្ឌកម្លាំងសាធារណ: ដើម្បីបំពេញមុខងាររបស់ខ្លួន
- ធ្វើការឆែកឆេរក្នុងផ្ទះ និងចាប់យកវត្ថុតាងទាំងឡាយដែលអាចបំភ្លឺការដល់ពិត
- សួរយកចម្លើយពីជនសង្ស័យ ឬសាក្សី និងធ្វើកោសល្យវិច្ច័យ។

បន្ទាប់ពីដឹងថាមានការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយភ្លាមព្រះរាជអាជ្ញាត្រូវចាត់វិធានការស៊ើបអង្កេតដែលច្បាប់ប្រគល់ឲ្យខ្លួន ក្នុងការរកឲ្យឃើញនូវការពិត។ ក្នុងការស៊ើបអង្កេតបឋមព្រះរាជអាជ្ញាអាចអនុវត្តបានតែចំពោះបទល្មើសឧក្រិដ្ឋ ឬបជ្ឈឹមជាក់ស្តែង

ដែលចៅក្រមស៊ើបអង្កេតពុំទាន់ទទួលបានសំណុំរឿងនៅឡើយ។ ចំពោះបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមមិនជាក់ស្តែង ព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតបឋមបានផងដែរក្នុងវិធានការស្វែងរកការពិត ។ ក្នុងការស៊ើបអង្កេតបឋមចំពោះបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម មិនជាក់ស្តែង នោះក្នុងគោលបំណងស្វែងរកសញ្ញាណនៃជនល្មើសដែលបានប្រព្រឹត្តបទល្មើស ដើម្បីឲ្យព្រះរាជអាជ្ញា មានមូលដ្ឋានគ្រប់គ្រាន់ក្នុងការធ្វើបណ្តឹងអាជ្ញាចោទប្រកាន់តាមរយៈ ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកជនល្មើសមកផ្តន្ទាទោសទៅតាមច្បាប់ ។

## កថាភាគទី ៣៖ អំណាចក្នុងការឃាត់ខ្លួន

តាមបទបញ្ញត្តិនៃមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០១០ ក្នុងការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌ ដែលរួមទាំងព្រះរាជអាជ្ញា អាចធ្វើការឃាត់ខ្លួនជនសង្ស័យថាបានចូលរួមក្នុងបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិម ជាក់ស្តែងតែប៉ុណ្ណោះ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនជនទាំងឡាយដែលអាចផ្តល់ពត៌មានស្តីពីរឿងហេតុដែលកើតឡើងបានចំពោះបុគ្គលដែលអាចផ្តល់ពត៌មាន តែប្រកែកមិនព្រមផ្តល់ពត៌មាន ដោយការឃាត់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញា ព្រមទាំងបញ្ជូនគ្រប់ភស្តុតាងទាំងអស់ជូនព្រះរាជអាជ្ញា ។ ការឃាត់ខ្លួនមានថេរវេលា ៤៨ ម៉ោង គិតចាប់ពីម៉ោងដែលសាមីខ្លួនបានមកដល់អង្គភាពនគរបាល ឬកងកម្លាំងអាវុធហត្ថ ។

ប្រសិនបើការឃាត់ខ្លួននេះបង្ហាញឲ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួនបានមន្ត្រីននគរបាលយុត្តិធម៌ អាចពន្យាពេលឃាត់ខ្លួនបាន ដែលមិនអាចឲ្យលើសពី ២៤ ម៉ោង ឡើយ ដោយមិនគិតពីថេរវេលាចាំបាច់ក្នុងការដឹកជញ្ជូន ។ ដោយការពន្យាពេលនេះត្រូវអនុញ្ញាដោយព្រះរាជអាជ្ញាដោយមានមូលហេតុ និងសំអាងច្បាស់លាស់ នៅក្នុងសំណុំរឿង ។

**ការឃាត់ខ្លួនអាចធ្វើទៅបាន៖**

- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោង ឡើយ ។

- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោង ឡើយ ។
- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោង ឡើយ ។
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោង ឡើយ ។
- អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។

### កថាភាគទី ៤៖ អំណាចក្នុងការបញ្ជូនខ្លួន

នៅពេលផុតកំណត់រយៈពេលដែលការឃាត់ខ្លួន បុគ្គលដែលជាជនសង្ស័យរូបនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនបុគ្គលនោះទៅព្រះរាជអាជ្ញា ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងក្នុងថ្ងៃតែមួយបានដោយមានការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវការដឹកជញ្ជូននោះបន្ថែមរយៈពេលបានដោយផ្តល់ដោយព្រះរាជអាជ្ញា។ ក្នុងករណីផុតរយៈពេលនៃការឃាត់ខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនត្រូវដោះលែងឲ្យមានសេរីភាព ដោយការសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា ។[12]

### កថាភាគទី ៥៖ អំណាចក្នុងការឆែកឆេរ

ព្រះរាជអាជ្ញា អាចចូលរួមក្នុងការឆែកឆេរ និងត្រួតពិនិត្យក្នុងករណីមានបទល្មើសឧក្រិដ្ឋជាក់ស្តែង ឬបទមជ្ឈិមជាក់ស្តែងកើតឡើងនៅក្នុងលំនៅដ្ឋានរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើស និងចាប់យកនូវវត្ថុតាងទាំងឡាយដែលអាចបំភ្លឺដល់ការពិត ។[13]

ដើម្បីឲ្យការឆែកឆេរនេះប្រព្រឹត្តតាមបញ្ញត្តិនៃច្បាប់ និងដើម្បីជៀសវៀង កុំឲ្យមានការរំលោភដល់សិទ្ធិសេរីភាព ទ្រព្យសម្បត្តិ និងកិត្តិយសសេចក្តីថ្លៃថ្នូរដល់ប្រជាពលរដ្ឋ ដោយការឆែកឆេរ ត្រូវធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និងមានសំអាងនៃមូលហេតុច្បាប់ និងអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។ ហើយការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ត្រូវធ្វើនៅចំពោះ

[12] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[13] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

មុខសាក្សីពីរនាក់ ដោយសាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ ហើយចំពោះសាក្សីមិនអាចជាកងកម្លាំងរាជអាវុធហត្ថ ដែលរួមប្រតិបត្តិក្នុងការឆែកឆេរបានឡើយ ។ ដោយការឆែកឆេរអាចអនុវត្តធ្វើទៅបានមុនម៉ោង ៦ ព្រឹក និងក្រោយ ម៉ោង១៨ ល្ងាចឡើយ ។

ការឆែកឆេរក៏អាចធ្វើភ្លាមៗបានដោយមិនចាំបាច់គោរពតាមលក្ខខណ្ឌខាងលើ ក្នុងករណីដូចខាងក្រោម ៖

- ក្នុងករណីមានសំរែកឲ្យគេជួយពីក្នុងទីកន្លែង
- ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន
- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ។

## ផ្នែកទី ២៖ ជម្រើសនៃការចោទប្រកាន់

អំណាចក្នុងការចោទប្រកាន់ គឺជាអំណាចផ្តាច់មុខរបស់អយ្យការ ។[14] ហើយអំណាចនៃការចោទប្រកាន់នេះត្រូវអនុវត្តដោយស្ថាប័នអយ្យការ គឺព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ការចោទប្រកាន់គឺជានីតិវិធីមួយដែលព្រះរាជអាជ្ញាមានសិទ្ធិសំរេចធ្វើ បណ្តឹងអាជ្ញាដើម្បីចោទប្រកាន់ទៅលើជនណាម្នាក់ដែលប្រព្រឹត្តបទល្មើស ឬក៏ច្រើននាក់ទៅសាលាជំរះក្តីលើករណីបទល្មើសព្រហ្មទណ្ឌទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដល់ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ពោលគឺការពារប្រព័ន្ធច្បាប់ឲ្យមានភាពរឹងមាំ ។ ជាគោលការណ៍សេចក្តីសំរេចនេះមុននឹងអនុវត្ត ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹង ដែលខ្លួនបានទទួលដោយផ្ទាល់ ឬដោយមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជូនមកឲ្យ ហើយព្រះរាជអាជ្ញាមានរយៈពេល ២ ខែ ដើម្បីសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដោយមុននិងសម្រេចបើកស៊ើបអង្កេតបឋមដោយខ្លួនឯង ឬបង្គាប់ឲ្យ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្រាវជ្រាវបន្ថែមជំនួស អាស្រ័យទៅតាមការយល់ឃើញរបស់ព្រះរាជអាជ្ញា ។

[14] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

## កថាភាគទី ១៖ ការតម្កល់រឿងទុកឥតចាត់ការ

- មូលហេតុដែលនាំឲ្យ ព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការរួមមាន៖
- មរណភាពនៃជនល្មើស
- បណ្ដឹងអាជ្ញាត្រូវបានផុតរលត់
- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ

ក្រៅពីមូលហេតុខាងលើនេះ ព្រះរាជអាជ្ញាអាចតម្កល់រឿងឥតចាត់ការបានដែរដូចជា៖

- អង្គហេតុនៃរឿងមិនមែនជារឿងព្រហ្មទណ្ឌ
- គោលការណ៍កាលានុវត្តភាព មានន័យថាអង្គហេតុនៃរឿងជារឿង ព្រហ្មទណ្ឌ ប៉ុន្តែវាជាបទល្មើសតូចតាច ។

ការតម្កល់រឿងទុកឥតចាត់ការត្រូវតែមានសម្អាងហេតុ និងសម្អាងច្បាប់ ហើយវាគ្មានអាជ្ញាអស់ជំនុំទេ មានន័យថាព្រះរាជអាជ្ញាអាចសើរើ កែប្រែ សេចក្ដីសម្រេចរបស់ខ្លួនវិញបានក្នុងករណីបណ្ដឹងអាជ្ញាមិនទាន់ផុតរលត់ ។ ប្រសិនបើអ្នកប្ដឹងនោះមិនសុខចិត្តនឹងសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ ព្រះរាជអាជ្ញាសាម៉ីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលឧទ្ធរណ៍បានក្នុងរយៈពេល ២ខែ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចនេះ ។

ប្រសិនបើ អគ្គព្រះរាជអាជ្ញាយល់ឃើញថាការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះ-រាជអាជ្ញាចេញអធិបញ្ញាជាលាយលក្ខណ៍អក្សរ ដល់ព្រះរាជអាជ្ញាអមសាលាដំបូងឲ្យធ្វើការចោទប្រកាន់ ។ នៅក្នុងករណីផ្ទុយពីនេះអគ្គព្រះរាជអាជ្ញាតម្កល់សេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ ។

## កថាភាគទី ២៖ ការចោទប្រកាន់

ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌអាចធ្វើបាន៖

- ការបើលការស៊ើបសួរ
- ការបញ្ជូនរឿងទៅជនុំជម្រះផ្ទាល់ ឬតាមនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។

## កថាភាគទី ៣៖ ការបើកការស៊ើបសួរ

ក្នុងករណីល្មើសបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិម ទាំងឡាយណាដែលមានភាពស្មុគស្មាញ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ហើយការស៊ើបសួរត្រូវបានបើកតាមដីការបញ្ជូនរឿងរបស់ព្រះរាជអាជ្ញាដែលត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ ។ ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ដោយចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន (ជនមិនស្គាល់អត្តសញ្ញាណ) ។[15]

**ដីបញ្ជូនរឿងឲ្យស៊ើបសួររួមមាន៖**

- សេចក្ដីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន

ដីការនេះត្រូវចុះ កាលបរិច្ឆេទ និងហត្ថលេខា។ ហើយទម្រង់នេះមានលក្ខណៈដាច់ខាតត្រូវតែគោរពបើពុំដូច្នោះត្រូវចាត់ទុកជាមោឃៈ។

## កថាភាគទី ៤៖ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ដីការកោះហៅបញ្ជូនរឿងឲ្យទៅជំនុំជម្រះផ្ទាល់គឺជា បញ្ជាឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការដំបូង ។

ដីការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន៖

- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្ដីសង្ខេបនៃអង្គហេតុ
- ឈ្មោះនៃបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា ។

ដីការនេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ ពេលនៃសវនាការ និងត្រូវបញ្ជាក់ថាជនជាប់ចោទអាចពឹងមេធាវីអមខ្លួនបាន ។

---
[15]មាត្រា ៤៤ , ៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

❖ **រយៈពេលដែលត្រូវគោរពសំរាប់ការប្រគល់ដីការកោះ**

- ១៥ ថ្ងៃប្រសិនជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជំបូង
- ២០ ថ្ងៃប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា
- ៣ ខែ ប្រសិនជនជាប់ចោទរស់នៅក្នុងរដ្ឋផ្សេងទៀត
- ក្នុងករណីជនជាប់ចោទត្រូវឃុំខ្លួន គ្មានរយៈពេលណាមួយត្រូវបានទាមទារឡើយ ។

ការប្រគល់ដីការកោះហៅបញ្ជូនទៅជំនុំជម្រះ ធ្វើឡើងដោយព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញា ក៏អាចសុំឲ្យអាជ្ញាសាលា អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថប្រគល់ដីការនេះជំនួសខ្លួនបានដែរ អ្នកទាំងនោះត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា ។ ប្រសិនបើអ្នកប្រគល់ជួបប្រទះជនជាប់ចោទនៅក្នុងផ្ទះ ឬនៅកន្លែងដ៏ទៃទៀត អាចប្រគល់ចុងដីការកោះហៅដល់សាមីខ្លួននោះ ដោយចាសេចក្ដីសម្រេចលើដើមដីកាថា បានប្រគល់ចុងដីកាដល់ជនជាប់ចោទផ្ទាល់ដៃ ហើយបានចុះនិទ្ទេសស្ដីពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់ ។ ជនជាប់ចោទចុះហត្ថលេខាលើដើមដីកា និងត្រូវបញ្ជូនវិលត្រឡប់ទៅព្រះរាជអាជ្ញាវិញភ្លាម ។

ប្រសិនបើជនជាប់ចោទអវត្តមានពីទីលំនៅរបស់ខ្លួន អ្នកប្រគល់ចុងដីកាឲ្យដល់បុគ្គលទាំងឡាយណាជា នីតិជន ដែលមានវត្តមាននៅទីលំនៅដ្ឋាននោះ ដោយអ្នកប្រគល់ដីកាត្រូវចុះនិទ្ទេសស្ដីពីអត្តសញ្ញាណនៃបុគ្គលនោះ និងកាលបរិច្ឆេទនៃការប្រគល់ដីកា ដោយបុគ្គលដែលត្រូវ ដែលទទួលចុងដីកាត្រូវទទួលចុះហត្ថលេខានៅលើដើមដីកា ដើម្បីបង្វិលទៅឲ្យព្រះរាជអាជ្ញាវិញ ។

ប្រសិនបើជនជាប់ចោទមិនព្រមទទួលដីកា ឬគ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅដ្ឋានរបស់ជនជាប់ចោទ ឬមានដែរតែមិនព្រមទទួលដីកា អ្នកប្រគល់ត្រូវប្រគល់ចុងដីកាឲ្យដល់ដៃ មេឃុំ ឬចៅសង្កាត់ ឬចៅសង្កាត់រង ។ អ្នកប្រគល់ត្រូវចុះនិទ្ទេសនៅលើដើមដីកាអំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា ។ ហើយបុគ្គលដែលទទួលចុងដីកាត្រូវចុះហត្ថលេខានៅលើដើមដីកាដែលត្រូវបង្វិលមកឲ្យព្រះរាជអាជ្ញាវិញ ។

ដោយបុគ្គលដែលទទួលដីកាត្រូវសន្យានឹងប្រគល់ដីកាដល់ជនជាប់ចោទនៅក្នុងរយៈពេលខ្លីបំផុត ។

## កថាភាគទី ៥៖ ការបង្ហាញខ្លួន

ព្រះរាជអាជ្ញា អាចបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលមកបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាសាលាដំបូងបាន ក្នុងករណីៈ

- បទល្មើសជាក់ស្តែង
- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ ឆ្នាំ និងយ៉ាងច្រើន ៥ ឆ្នាំ
- ជនជាប់ចោទជានីតិជន
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបាន
- នីតិវិធីក្នុងការបង្ហាញខ្លួនភ្លាម ។

  ក្នុងរឿងក្តីព្រហ្មទណ្ឌ កាលណាសម្រេចត្រូវប្រើនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាមព្រះរាជអាជ្ញាត្រូវៈ

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនខ្លួនយកមកឲ្យ
- ឲ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលត្រូវចោទប្រកាន់ និងឈ្មោះនៃបទល្មើស
- ទទួលចម្លើយបុគ្គលនោះ បើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីពី ការបង្គាប់ឲ្យចូលមកបង្ហាញខ្លួនភ្លាម
- ប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។
- មេធាវីជ្រើសរើស ឬចាត់តាំងត្រូវបានទទួលដំណឹងភ្លាម ហើយអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន ។ និទ្ទេសនៃទម្រង់ការទាំងនេះត្រូវចុះកំណត់ហេតុ បើពុំដូច្នោះទេ និតីវិធីត្រូវចាត់ទុកជាមោឃៈ ។
- ឲ្យដំណឹងទៅតុលាការ តាមកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម
- បង្ខាំងជនជាប់ចោទទុក ដោយមានកងកម្លាំងការពាររហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅថ្ងៃនោះតែម្តង

- នៅពេលបង្ហាញខ្លួន តុលាការត្រូវផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជននោះ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ ហើយប្រាប់ជននោះថា សាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន
- ប្រសិនជនជាប់ចោទ សុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថារឿងក្តីនោះមិនអាចជំនុំជម្រះភ្លាមៗបានទេនោះសំណុំរឿងត្រូវលើកទៅ សវនាការនៅពេលក្រោយ ហើយតុលាការអាចបង្គាប់ឲ្យឃុំខ្លួនជននោះជាបណ្តោះអាសន្ន ដោយសាលក្រមដែលមានបញ្ជាក់ពីសំអាងហេតុ ។
- សាលក្រមលើអង្គហេតុសេចក្តី ត្រូវតែប្រកាសក្នុងរយៈពេលមិនអាចខានលើសពី ២ សប្តាហ៍ គិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ
- បើផុតរយៈពេល ២ សប្តាហ៍ ការឃុំខ្លួនត្រូវតែបញ្ឈប់ដោយពេញច្បាប់ ។
- ប្រសិនបើតុលាការយល់ឃើញថា លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាមមិនបានបំពេញទេ ឬក៏មានភាពស៊ាំញ៉ាំតម្រូវចាំបាច់ឲ្យធ្វើការស្រាវជ្រាវបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅឲ្យព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ ។ ជនជាប់ចោទត្រូវនាំទៅចំពោះមុខចៅក្រមស៊ើបសួរនៅថ្ងៃនោះតែម្តង បើពុំដូច្នោះទេត្រូវតែដោះលែងឲ្យមានសេរីភាពវិញដោយឯកឯង ។

**រយៈពេលដែលត្រូវគោរពសំរាប់ការប្រគល់ដីការកោះ**

- ១៥ ថ្ងៃប្រសិនជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការដំបូង
- ២០ ថ្ងៃប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា
- ៣ ខែ ប្រសិនជនជាប់ចោទរស់នៅក្នុងរដ្ឋផ្សេងទៀត
- ក្នុងករណីជនជាប់ចោទត្រូវឃុំខ្លួន គ្មានរយៈពេលណាមួយត្រូវបានទាមទារឡើយ ។

ការប្រគល់ដីការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ធ្វើឡើងដោយព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញា ក៏អាចសុំឲ្យអាជ្ញាសាលា អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថប្រគល់ដីការនេះជំនួសខ្លួនបានដែរ អ្នកទាំងនោះត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា ។ ប្រសិនបើអ្នកប្រគល់ជួបប្រទះជនជាប់ចោទនៅក្នុងផ្ទះ ឬ

នៅកន្លែងដ៏ទៃទៀត អាចប្រគល់ចុងដីការកោះហៅដល់សាមីខ្លួននោះ ដោយចាសេចក្តីសម្រេចលើដើមដីកាថា បានប្រគល់ចុងដីកាដល់ជនជាប់ចោទផ្ទាល់ដៃ ហើយបានចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់ ។

ប្រសិនបើជនជាប់ចោទអវត្តមានពីទីលំនៅរបស់ខ្លួន អ្នកប្រគល់ចុងដីកាឲ្យដល់បុគ្គលទាំងឡាយណាជា នីតិជន ដែលមានវត្តមាននៅទីលំនៅដ្ឋាននោះ ដោយអ្នកប្រគល់ដីកាត្រូវចុះនិទ្ទេសស្តីពីអត្តសញ្ញាណនៃបុគ្គលនោះ និងកាលបរិច្ឆេទនៃការប្រគល់ដីកា ដោយបុគ្គលដែលត្រូវ ដែលទទួលចុងដីកាត្រូវទទួលចុះហត្ថលេខានៅលើដើមដីកា ដើម្បីបង្វិលទៅឲ្យព្រះរាជអាជ្ញាវិញ ។

ដោយបុគ្គលដែលទទួលដីកាត្រូវសន្យានឹងប្រគល់ដីកាដល់ជនជាប់ចោទនៅក្នុងរយៈពេលខ្លីបំផុត ។

ប្រសិនបើជនជាប់ចោទមិនព្រមទទួលដីកា ឬគ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅដ្ឋានរបស់ជនជាប់ចោទ ឬមានដែរតែមិនព្រមទទួលដីកា អ្នកប្រគល់ត្រូវប្រគល់ចុងដីកាឲ្យដល់ដៃ មេឃុំ ឬចៅសង្កាត់ ឬចៅសង្កាត់រង ។ អ្នកប្រគល់ត្រូវនិទ្ទេសនៅលើ ដីកាអំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា ។ ហើយបុគ្គលដែលទទួលចុងដីកាត្រូវចុះហត្ថលេខានៅលើដើមដីការដែលត្រូវបង្វិលមកឲ្យព្រះរាជអាជ្ញាវិញភ្លាម ហើយបុគ្គលដែលទទួលដីកាត្រូវសន្យាថានឹងប្រគល់ដីកានេះក្នុងរយៈពេលខ្លីបំផុតដល់ជនជាប់ចោទ ។

ប្រសិនបើជនជាប់ចោទគ្មានលំនៅដ្ឋាន ឬសំណាក់ ឬរស់នៅក្រៅដែនដីជាតិកាលបរិច្ឆេទនៃការធ្វើដីកាត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការប្រគល់ដីកា ។

## ផ្នែកទី ៣៖ តួនាទីរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

តួនាទីរបស់អគ្គអមសាលាឧទ្ធរណ៍ គឺជាអ្នកឃ្លាំមើលការអនុវត្តច្បាប់ នៅក្នុងសមត្ថកិច្ចដែលដីនៃសាលាឧទ្ធរណ៍ និងអាចធ្វើអធិការកិច្ចនៅអង្គការអយ្យការទាំងឡាយដែលនៅក្នុងដែនដីរបស់ខ្លួន និងក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាបន្ទាន់ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាអ្នកឃ្លាំមើល និងត្រួតពិនិត្យលើនគរបាលយុត្តិធម៌ ចំពោះការប្រព្រឹត្តទៅរបស់នគរបាលយុត្តិធម៌ និងអាចធ្វើការកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនេះដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងអង្គភាពនេះផងដែរ។ ក្នុងនោះផងដែរអគ្គព្រះរាជអាជ្ញា អាចប្រគល់ភារកិច្ចដល់មន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ឲ្យបំពេញកិច្ចការទាំងឡាយណាដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការគ្រប់គ្រងឬដំណើរការល្អនៃនគរបាលយុត្តិធម៌ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក៏អាចធ្វើអធិការកិច្ចនៅគ្រប់ពេលវេលាដែរនៅអង្គភាពនគរបាលយុត្តិធម៌ ហើយ និងអាចចូលរួមក្នុងការស្តាប់ចម្លើយ ត្រួតពិនិត្យចំពោះការអនុវត្តវិធានការឃាត់ខ្លួនគឺត្រូវគោរពទៅតាមទម្រង់ច្បាប់ ។

## កថាភាគទី ១៖ តួនាទីរបស់អគ្គព្រះរាជអាជ្ញាចំពោះសេចក្តីសម្រេចរបស់ចៅក្រម

ក្នុងរឿងក្តីព្រហ្មទណ្ឌ កាលណាតុលាការចេញសេចក្តីសម្រេច ក្នុងករណីសាមីខ្លួនដែលជាជនរងគ្រោះមិនសុខចិត្តនិងសេចក្តីសម្រេចនេះរបស់តុលាការជាន់ទាប ជនរងគ្រោះអាចធ្វើការប្តឹងទៅសាលាឧទ្ធរណ៍ ដែលបណ្តឹងនេះគេហៅថាបណ្តឹងឧទ្ធរណ៍ ដោយនីតិវិធីនៃការប្តឹងត្រូវធ្វើឡើងដោយ៖

- **ព្រះរាជអាជ្ញានៃតុលាការដំបូង:** បណ្តឹងឧទ្ធរណ៍ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រមក្នុងរយះពេល ១ ខែ ដែលគិតចាប់ពីពេលប្រកាសសាលក្រម ។
- **អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍:** បណ្តឹងឧទ្ធរណ៍ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃសលាឧទ្ធរណ៍ក្នុងរយះពេល ៣ ខែ ដែលគិតចាប់ពីពេលប្រកាសសាលក្រម ។
- **ពិរុទ្ធជន:** ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលប្រកាសសាលក្រមក្នុងរយះពេល ១ ខែ ដែលគិតចាប់ពីពេលប្រកាសសាលក្រម (ចំពោះសាលក្រមចំពោះមុខ) និងគិតពីពេលទទួលដំណឹងអំពីសាលក្រម ។ ពិរុទ្ធជនអាចត្រូវតំណាងដោយមេធាវី ដោយមេធាវីត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើបណ្តឹងឧទ្ធរណ៍នេះ ។ ក្នុងករណីពិរុទ្ធជនជាអ

នីតិជន អាចតំណាងដោយឪពុក ម្តាយ ឬអាណាព្យាបាល ដោយករណីនេះអ្នកតំណាង មិនចាំបាច់មានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍ទេ ។

នៅពេលសាលាឧទ្ធរណ៍បាន ទទួលបណ្តឹងឧទ្ធរណ៍ពីជនជាប់ចោទសាលាឧទ្ធរណ៍អាច កំណត់បទល្មើស និងប្តូរឈ្មោះបទល្មើសដែលកំណត់ដោយសាលាដំបូងទៅជាបទល្មើស មួយទៀតបាន តែមិនអាចដាក់ទម្ងន់ទោសលើជនជាប់ចោទ និងមិនអាចបន្ថែមចំនួនទឹក ប្រាក់ សម្រាប់ការជួសជុលការខូចខាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានទេ។

- **ដើមបណ្តឹងរដ្ឋប្បវេណី:** ត្រូវធ្វើឡើងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែល ប្រកាសសាលក្រមក្នុងរយៈពេល ១ ខែ គិតពីពេលប្រកាសសាលក្រម (ក្នុងករណី សាលក្រមកំបាំងមុខ) និងគិតពីពេលទទួលដំណឹងអំពីសាលក្រម (ក្នុងករណីសាល ក្រមចាត់ទុកចំពោះមុខ) ។

ដើមបណ្តឹងរដ្ឋប្បវេណី អាចតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ដោយត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើបណ្តឹងឧទ្ធរណ៍។ បើរក្រឡេកទៅមើលបណ្តឹងឧទ្ធរណ៍ របស់ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបានតែលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីតែប៉ុណ្ណោះ។

- **អ្នកទទួលខុសត្រូវរដ្ឋប្បវេណី:** ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែល ប្រកាសសាលក្រម ក្នុងរយៈពេល ១ ខែ គិតពីពេលប្រកាសសាលក្រម (ក្នុងករណី សាលក្រមចំពោះមុខ) និងគិតពីពេលទទួលដំណឹងសាលក្រម (ក្នុងករណីសាលក្រម ចាត់ទុកចំពោះមុខ) ។

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី ឬសហព័ទ្ធ ឬញាតិលោហិត ផ្ទាល់ ដោយត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើបណ្តឹងឧទ្ធរណ៍។ ចំពោះបណ្តឹងឧទ្ធរណ៍របស់ អ្នកទទួលខុស ត្រូវរដ្ឋប្បវេណីអាចធ្វើបានតែលើផលប្រយោជន៍ផ្នែក ដែល ទាក់ទង ទៅនឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។

### ១.១-រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍

ក្នុងករណីបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃតុលាការដំបូងរៀបចំសំណុំរឿងក្នុងរយៈពេល ខ្លីបំផុតជូនដល់ការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍នូវៈ

- សំណុំរឿងនៃនីតិវិធី

- សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍នីមួយៗ ដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។
- សេចក្តីចម្លងនៃសាលក្រមដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ។

នៅក្នុងករណីមានបណ្តឹងឧទ្ធរណ៍សេចក្តីសម្រេចរបស់តុលាការ ស្តីពីការឃុំខ្លួនជនជាប់ចោទសំណុំរឿងត្រូវបញ្ជូនក្នុងរយៈពេល ១០ ថ្ងៃ យ៉ាងយូរគិតពីថ្ងៃប្តឹងឧទ្ធរណ៍ តែក្នុងករណីកាលៈទេសៈមិនអាចជម្រះបានត្រូវតែបញ្ជាក់ក្នុងលិខិតបញ្ជូន ។

នៅពេលសំណុំរឿងទៅដល់សាលាឧទ្ធរណ៍ ប្រធានសភាព្រហ្មទណ្ឌពិនិត្យផ្ទៀងផ្ទាត់មើលថាតើត្រឹមត្រូវទៅតាមទម្រង់នៃបែបបទបណ្តឹងឬទេ និងកំណត់ទៅលើកាលបរិច្ឆេទសវនាការ ចំពោះកាលបរិច្ឆេទនៃសវនាការនោះ និងតាមរយៈពេលជំនុំជម្រះប្រធានសភាព្រហ្មទណ្ឌជូនដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ បន្ទាប់ពីបានទទួលដំណឹងពីប្រធានសភា អគ្គព្រះរាជអាជ្ញាកោះហៅជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អោយចូលសវនាការ ។

## ១.២-អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា

នៅពេលមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជាអាជ្ញា នាំឲ្យមានការសើរើឡើងនូវសេចក្តីសម្រេចរបស់តុលាការដំបូង ។ ក្នុងរយៈពេលប្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបានបង្អង់សិន គឺព្យួរសេចក្តីសម្រេចក្នុងសាលក្រម ។ ប៉ុន្តែជនជាប់ចោទដែលត្រូវឃុំនៅក្នុងពន្ធនាគារ ដែលបានចូលបង្ហាញខ្លួននៅមុខតុលាការដំបូងត្រូវនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងត្រូវនៅក្នុងពន្ធនាគារដដែលរហូតដល់ពេលសាលាឧទ្ធរណ៍សម្រេចក្នុងករណី មានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងព្រហ្មទណ្ឌ ដែលជាបណ្តឹងរបស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញា ក៏អាចធ្វើការដោះលែងជនជាប់ចោទឲ្យមានសេរីភាពបានមុនពេលផុតកំណត់នៃរយៈពេលប្តឹងឧទ្ធរណ៍ ក្នុងករណីដែលតុលាការដំបូងបានសម្រេច ឬបានធ្វើការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលតិចជាង ឬស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ។

## ផ្នែកទី ៤៖ តួនាទីរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

តួនាទីរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាអ្នកចូលរួមក្នុងការសុំឲ្យមានការគោរពច្បាប់នៅក្នុងពេលដែលមានបណ្តឹងសាទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀត ដើម្បីដាក់ជូនតុលាការកំពូលពិនិត្យ ។

# ជំពូកទី ៣
# ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ព្រះរាជអាជ្ញា

ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ព្រះរាជអាជ្ញាត្រូវយោងទៅតាមលក្ខខណ្ឌនៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិតាមវេនជ្រើសរើស និងតាមវេនអតិតភាពដែលបានធ្វើឡើងដោយ ព្រះរាជក្រឹត្យ។ ដូចនេះការធ្វើការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិរបស់ព្រះរាជអាជ្ញានេះត្រូវយោងទៅតាមអនុក្រឹត្យដែលបានចេញ និងត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមវេនអតីតភាពស្របតាមអ្វីដែលបានចែងនៅក្នុងតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗនោះ។

មូលហេតុក្នុងការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ព្រះរាជអាជ្ញាត្រូវផ្អែកទៅលើគោលការណ៍មួយចំនួនដូចខាងក្រោមនេះ៖

- ការគោរពវិន័យការងារបានត្រឹមត្រូវ
- ការសម្រេចភារកិច្ចបានល្អ
- កិរិយាមាយាទ និងសីលធម៌ល្អ មិនធ្វើឲ្យប៉ះពាល់ទៅលើកិត្តិយសនៃអង្គចៅក្រម
- ទទួលការឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា។

ដូចនេះនៅក្នុងពេលបំពេញការងារ ព្រះរាជអាជ្ញាដែលបានខិតខំក្នុងការបំពេញការងារបានល្អដែលមានមាយាទ និងសីលធម៌ល្អ ឬទទួលបានសញ្ញាបត្រក្រោយឧត្តមសិក្សានោះនឹងត្រូវទទួលបានការលើកទឹកចិត្តដោយធ្វើការដំឡើងថ្នាក់ថែម ១ ( មួយ ) ថ្នាក់។

ទោះយ៉ាងណាក៏ដោយ ការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិរបស់ព្រះរាជអាជ្ញានេះមិនត្រូវធ្វើឡើងតាមតែការចង់នោះទេ។ ថ្នាក់ និងឋានន្តរស័ក្តិនីមួយៗនៃឋានានុក្រម ចំនួនព្រះរាជអាជ្ញាដែលគ្រោងនឹងឡើងថ្នាក់នេះត្រូវធ្វើឡើងឲ្យស្របទៅតាមតម្រូវការ នៃការងារដោយយោងទៅតាមគម្រោងថវិកាជាតិ។ ព្រះរាជអាជ្ញានីយមួយៗអាចត្រូវបានដំឡើងថ្នាក់ ឬឋានន្តរស័ក្តិបានម្តងត្រឹមតែ ១ ( មួយ ) ថ្នាក់តែប៉ុណ្ណោះ មិនអាចលើសពីនេះបានទេ។ បើក្នុងករណីចាំបាច់នោះ ព្រះរាជអាជ្ញាអាចធ្វើការដំឡើងថ្នាក់បានដោយការធ្វើការប្រឡង។ ដើម្បីធ្វើការប្រឡងប្រជែងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិនេះ ព្រះរាជអាជ្ញាស្វែងរកឈ្មោះរបស់

ខ្លួននៅក្នុងតារាងដំឡើងថ្នាក់ ក៏ប៉ុន្តែ ព្រះរាជអាជ្ញារូបនោះត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមដើម្បីមានឈ្មោះនៅក្នុងតារាដំឡើងថ្នាក់នោះ៖

- ព្រះរាជអាជ្ញាដែលបានបម្រើការងារក្រោយពីបានតាំងស៊ប់
- ស្ថិតនៅក្នុងឋានន្តរស័ក្តិ ឬថ្នាក់របស់ខ្លួនយ៉ាងតិច ២ ( ពីរ ) ឆ្នាំ គិតមកទល់ថ្ងៃទី ១៣ មេសា នៃឆ្នាំនីមួយៗ។

បើព្រះរាជអាជ្ញាមានលក្ខណៈសម្បត្តិដូចខាងលើនេះ ហើយបានធ្វើការស្នើរដំឡើងថ្នាក់នោះ ឈ្មោះរបស់ព្រះរាជអាជ្ញារូបនោះនឹងត្រូវធ្វើការកត់ត្រានៅក្នុងតារាងដំឡើងថ្នាក់ដែលតារាងនេះត្រូវបានធ្វើឡើងតាមលំដាប់អតិតភាពស្របតាមតារាងនៃថ្នាក់នីមួយៗនោះ។ បន្ទាប់មកតារាងដំឡើងថ្នាក់នោះ នឹងត្រូវបិទប្រកាសឲ្យសាមីជនដឹងនៅតាមសាលាជម្រះក្តីនីមួយៗ។ នៅក្នុងករណីដែលព្រះរាជអាជ្ញាដែលមានអតីតភាពគ្រប់កំណត់នោះបានធ្វើការស្នើរដំឡើងថ្នាក់ហើយ ប៉ុន្តែពុំឃើញឈ្មោះរបស់ខ្លួននៅក្នុងតារាងដំឡើងថ្នាក់នោះទេ ព្រះរាជអាជ្ញារូបនោះអាចធ្វើការប្តឹងតវ៉ាសុំឲ្យ ចុះឈ្មោះរបស់ខ្លួនទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃចាប់ពីថ្ងៃទទួលបានដំណឹងអំពីតារាងស្នើដំឡើងថ្នាក់នោះ ហើយបើរផុតរយៈពេលដែលបានកំណត់នេះទៅ និងត្រូវចាត់ទុកជាអសាបង់។

ក្នុងការធ្វើការប្រឡងដំឡើងថ្នាក់របស់ព្រះរាជអាជ្ញានេះ ដើម្បីអោយមានភាពសុក្រឹតនោះ ការធ្វើការប្រឡងនេះត្រូវមានគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិដែលមានសមាសភាពដូចខាងក្រោម៖

- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១ ( មួយ ) រូប ជាប្រធាន
- អនុប្រធានតុលាការកំពូល ១ ( មួយ ) រូប ជាអនុប្រធាន
- អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ១ ( មួយ ) រូប ជាអនុប្រធាន
- ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ ជាសមាជិក
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ ជាសមាជិក
- ប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាសមាជិក
- ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ជាសមាជិក

- និង អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាលេខាធិការ។

នៅក្នុងករណីអវត្តមាន ឬមានបញ្ហាជាបន្ទាន់ដែលពុំអាចចូលរួមបាននោះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចតាក់តែងសមាភាពផ្សេងទៀតក្នុងការជំនួសការឲ្យគណៈកម្មការនេះទៅតាមការចាំបាច់។

ព្រឹត្តិបត្រឯកត្តជនរបស់ព្រះរាជអាជ្ញា ដែលបានចុះឈ្មោះក្នុងបញ្ជីនៃថ្នាក់នីយមួយៗនោះ និងព្រឹត្តិបត្រឯកត្តជនរបស់ព្រះរាជអាជ្ញាដែលបានប្ដឹងតវ៉ាទាំងនោះ និងត្រូវបញ្ជូនទៅគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិដែលបានបង្ហាញនៅខាងលើនេះឲ្យបានក្នុងសប្តាហ៍ទី ២ ខែ កុម្ភៈ នៃឆ្នាំនោះ។ បន្ទាប់មក ប្រធានគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ នឹងធ្វើការកោះអញ្ជើញគណៈកម្មការខាងលើមកប្រជុំអោយបានមុនថ្ងៃចូលឆ្នាំខ្មែរ។ បន្ទាប់ពីបានមើលនិងពិនិត្យទៅលើព្រឹត្តិបត្រឯកត្តជន និងសម្រេចទៅលើបណ្ដឹងតវ៉ា និងក្រោយពីបានស្តាប់សេចក្តីពន្យល់របស់ប្រធានរួចរាល់ហើយនោះ សមាជិកម្នាក់ៗនិងធ្វើការដាក់ពិន្ទុពី ០ ( សូន្យ ) ដល់ ២០ ( ម្ភៃ ) ឲ្យព្រះរាជអាជ្ញាបេក្ខជនម្នាក់ៗ។ នៅរៀងរាល់ឆ្នាំនៅសប្តាហ៍ទី ១ ខែមករា ព្រះរាជអាជ្ញានីមួយៗនិងត្រូវទទួលបាននូវព្រឹត្តិបត្រឯកត្តជនដែលព្រះរាជអាជ្ញាទាំងនោះត្រូវបំពេញទៅតាមចំណុចសំណួរនីយមួយៗ។ ការចុះឈ្មោះនៅក្នុងតារាងបេក្ខជននេះត្រូវបានធ្វើឡើងទៅតាមលំដាប់ នៃគុណសម្បត្តិទាំងអស់របស់ព្រះរាជអាជ្ញាបេក្ខជននីមួយៗនៃលទ្ធផលពិន្ទុសរុប ប្រសិនបើមានព្រះរាជអាជ្ញាបេក្ខជនណាមួយទទួលបានពិន្ទុស្មើរគ្នានោះ បេក្ខជនដែលមានអាយុច្រើនជាងនោះនឹងត្រូវទទួលបានការចុះឈ្មោះមុនគេនៅក្នុងបញ្ជី។ ព្រះរាជអាជ្ញា នឹងត្រូវផ្អាកមិនទាន់ឲ្យមានសិទ្ធិក្នុងការចុះឈ្មោះនៅក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិនោះទេប្រសិនបើព្រះរាជអាជ្ញារូបនោះកំពុងជាប់ក្នុងការអង្កេតជាបទវិន័យ ឬបទល្មើសព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាបេក្ខជនដែលពុំបានជាប់ឈ្មោះដំឡើងថ្នាក់ ឬឋានន្តរស័ក្តិនោះទេ បេក្ខជននោះត្រូវមានអាទិភាពចុះឈ្មោះមុនគេនៅក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិឆ្នាំក្រោយ។

ព្រឹត្តិបត្រឯកត្តជននេះត្រូវធ្វើការដាក់ពិន្ទុដោយមានបញ្ជាក់ពីយោបល់ និងមូលហេតុឲ្យបានច្បាស់លាស់។ ការដាក់ពិន្ទុត្រូវធ្វើឡើងដូចខាងក្រោមនេះ៖

- ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូង ត្រូវដាក់ពិន្ទុដោយព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។
- ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ត្រូវដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។
- ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមតុលាការកំពូលត្រូវដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមតុលការកំពូល។
- ព្រះរាជអាជ្ញាដែលបានផ្លាស់ឲ្យទៅបំពេញភារកិច្ចនៅស្ថាប័នផ្សេងនោះ ត្រូវដាក់ពិន្ទុដោយប្រធានស្ថាប័ននោះ។

គណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមានតួនាទីក្នុងការរៀបចំតារាងទៅតាមជំនាន់ព្រះរាជអាជ្ញាដែលដំឡើងថ្នាក់ និងឋានន្តរស័ក្តិនៅក្នុងតារាងឈ្មោះនោះ ហើយដាក់ជូនទៅឲ្យ ឧត្តមក្រុមព្រឹក្សានៃអង្គចៅក្រមត្រួតពិនិត្យ និងផ្តល់យោបល់។ ចំណែកឯអគ្គលេខាធិកានៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនោះ ត្រូវរៀបចំតារាងឈ្មោះព្រះរាជអាជ្ញាដែលត្រូវដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីធ្វើការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ។[16]

## ផ្នែកទី ១៖ ការតែងតាំង ផ្លាស់ប្តូរ ផ្តាច់ពីមុខងារ ដាក់ឲ្យនៅក្រៅក្របខណ្ឌ ដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចោលរបស់ព្រះរាជអាជ្ញា

យោងទៅតាមការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចោលរបស់ព្រះរាជអាជ្ញានេះត្រូវបានធ្វើឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយធ្វើការលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រទាក់ទងទៅលើបញ្ហាទាំងអស់ខាងលើនេះ ដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវធ្វើការពិគ្រោះយោបល់អោយបានច្បាស់លាស់និងក្បោះក្បាយ ទៅលើបញ្ហារទាំងនោះមុននិងធ្វើការសម្រេចចិត្ត។ ចំណែកឯរដ្ឋមន្ត្រីក្រសួងយុត្តិធម៌គឺជាអ្នកលើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយទៅព្រះមហាក្សត្រ។

---

[16] មាត្រា ៨៦-៨៨, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ ២០១៤

### កថាភាគទី ១៖ការសុំផ្អាច់ពីមុខខារ

ដើម្បីឲ្យព្រះរាជអាជ្ញាធ្វើការសុំផ្អាច់ពីមុខងារបាននោះ ព្រះរាជអាជ្ញាត្រូវមានហេតុផលក្នុងករណីចាំបាច់ក្នុងការបំពេញការងារជាបណ្ដោះអាសន្នដូចតទៅ៖

- ក្នុងតំណែងមុខងារសាធារណ:
- តំណាងរាស្ត្រ
- សមាជិកព្រឹទ្ធសភា
- សមាជិករាជរដ្ឋភិបាល
- អនុរដ្ឋលេខាធិការ
- មុខងារទទួលអាណត្តិដោយការបោះឆ្នោតដ៏ទៃទៀត ឬតំណែងទីប្រឹក្សាគ្រប់ឋានានុក្រម។

ដើម្បីធ្វើអោយការសុំផ្អាច់ពីមុខងារនេះធ្វើទៅបាននោះ ការអនុញ្ញាតឲ្យផ្អាច់ពីមុខងារនេះត្រូវទទួលបានទៅតាមសំណើរបស់សាមីខ្លួន ( ព្រះរាជអាជ្ញា ) ឬទៅតាមស្ថាប័នផ្សេងៗទៀតដែលទទួលបានការយល់ព្រមរបស់សាមីខ្លួន ( ព្រះរាជអាជ្ញា )។ នៅក្នុងអំឡុងពេលទទួលបានការផ្អាច់ពីមុខងាររបស់ព្រះរាជអាជ្ញានេះ ព្រះរាជអាជ្ញារូបនោះនឹងនៅតែទទួលបានប្រាក់បៀវត្ស សិទ្ធិក្នុងការឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងសិទ្ធិក្នុងការចូលនិវត្តន៍ផងដែរ ក៏ប៉ុន្តែ ពុំត្រូវទទួលបានប្រាក់បំណាច់មុខងារនិងប្រាក់រង្វាន់ផ្សេងៗទៀតនៃមុខងារដើមរបស់ខ្លួននោះទេ។

### កថាភាគទី ២៖ការសុំនៅក្រៅក្របខណ្ឌ

ដើម្បីឲ្យព្រះរាជអាជ្ញាធ្វើការសុំនៅក្រៅក្របខណ្ឌបាននោះ ព្រះរាជអាជ្ញាត្រូវមានហេតុផលក្នុងករណីចាំបាច់ក្នុងការបំពេញការងារជាបណ្ដោះអាសន្នដូចតទៅ៖

- ការងារជាបណ្ដោះអាសន្ននៅក្នុងសហគ្រាសសាធារណ:
- ឬនៅតាមអង្គការអន្តរជាតិ។

ដើម្បីធ្វើអោយការសុំនៅក្រោមក្របខណ្ឌ នេះធ្វើទៅបាននោះ ការអនុញ្ញាតឲ្យផ្អាច់ពីមុខងារនេះត្រូវទទួលបានទៅតាមសំណើររបស់សាមីខ្លួន ( ព្រះរាជអាជ្ញា ) ឬទៅតាមស្ថាប័នផ្សេងៗទៀតដែលទទួលបានការយល់ព្រមរបស់សមីខ្លួន ( ព្រះរាជអាជ្ញា )។

នៅក្នុងអំឡុងពេលទទួលបានការនៅក្រៅក្របខណ្ឌ របស់ព្រះរាជអាជ្ញានេះព្រះរាជ-អាជ្ញារូបនោះមិនត្រូវទទួលបានប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗទៀតនោះទេ។

ព្រះរាជអាជ្ញា នឹងត្រូវធ្វើការផ្អាកពីមុខងារជាបណ្ដោះអាសន្ន នៅក្នុងករណីដែលព្រះរាជអាជ្ញារូបនោះកំពុងជាប់នៅក្នុងនីតិវិធីវិន័យរបស់ក្រុមប្រឹក្សានៃអង្គចៅក្រម ដែលការផ្អាកពីមុខងារដោយបណ្ដោះអាសន្ននេះត្រូវធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## កឋាខណ្ឌទី ៣៖ ការស្នើសុំនៅទំនេរគ្មានបៀវត្ស

ដើម្បីព្រះរាជអាជ្ញាការធ្វើការស្នើរសុំនៅទំនេរគ្មានបៀវត្សនេះ ព្រះរាជអាជ្ញាត្រូវមានហេតុផលក្នុងករណីចាំបាច់ ដូចតទៅ៖

- មូលហេតុផ្ទាល់ខ្លួន
- គ្រួសារ ឬវិសមិតភាព

ក្នុងករណីនេះ ព្រះរាជអាជ្ញាអាចធ្វើការស្នើសុំដោយសាមីខ្លួនទៅលើការសុំនៅទំនេរគ្មានបៀវត្សបានប៉ុន្តែការធ្វើការសុំនៅទំនេរគ្មានបៀវត្សនេះអាចធ្វើឡើងបានម្តង ១ ( មួយ ) ទៅ ២ ( ពីរ ) ឆ្នាំ ប៉ុណ្ណោះ ដែលការអនុញ្ញាតអោយនៅទំនេរគ្មានបៀវត្សនេះអាចធ្វើទៅបានត្រឹមតែ ២ ( ពីរ ) ដងគត់ដែលរយៈពេលសរុបរួមនៃការសុំនៅទំនេរគ្មានបៀវត្សនេះមិនត្រូវលើសពី ៤ ( បួន ) ឆ្នាំ នោះទេ។ ដើម្បីទទួលបានការអនុញ្ញាតអោយនៅទំនេរគ្មានបៀវត្សបាននោះ ព្រះរាជអាជ្ញារូបនោះត្រូវបានបំពេញការងារអស់រយៈពេលយ៉ាងតិច ៤ ( បួន ) ឆ្នាំ ដោយមិនគិតទៅលើព្រះរាជអាជ្ញាដែលត្រូវទទួលទណ្ឌកម្មវិន័យថ្នាក់ទី ២ ( ពីរ ) នោះទេ។ ព្រះរាជអាជ្ញាដែលមានបំណងធ្វើការស្នើរសុំនៅទំនេរគ្មានបៀវត្ស ត្រូវធ្វើការស្នើរសុំជាលាយលក្ខណ៍អក្សរដោយសាមីខ្លួន ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យមើល និងចាត់ការទៅតាមនីតិវិធី។

នៅក្នុងអំឡុងពេលទទួលបានការនៅទំនេរគ្មានបៀវត្ស បើមានបំណងក្នុងការបន្ត ឬសុំចូលបម្រើការងារដូចធម្មតាវិញត្រូវធ្វើការដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬការសុំចូលបម្រើការងារដូចធម្មតាវិញអោយបាន ២ ( ពីរ ) ខែ មុនពេលផុតកំណត់នៃរយៈពេលដែលបានសុំនៅទំនេរគ្មានបៀវត្សនោះ។ នៅក្នុងករណីដែលព្រះរាជអាជ្ញារូបនោះពុំបាន

ដាក់ពាក្យសុំបន្តការនៅទំនេរគ្មានបៀវត្ស ឬក៏ ពុំមកធ្វើការដូចធម្មតាវិញអស់រយៈពេលលើសពី ៣០ ( សាមសិប ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានផុតរយៈពេលសុំការនៅទំនេរគ្មានបៀវត្ស និងត្រូវលុបឈ្មោះចេញពីក្របខណ្ឌចាប់ពីថ្ងៃនោះតទៅ។

## ផ្នែកទី ២៖ ទណ្ឌកម្មវិន័យ និងការលុបឈ្មោះរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញានឹងត្រូវទទួលទណ្ឌកម្មវិន័យបើសិនជាកំហុសទាំងនោះទាក់ទងនៅនឹង៖

- ការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ
- ការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ ស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាស់ចាកពីក្រមសីលធម៌របស់ព្រះរាជអាជ្ញា។

ក៏ប៉ុន្តែ នៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាទៅលើការអនុវត្តច្បាប់ មិនត្រូវរាប់បញ្ចូលថាជាកំហុសខាងវិន័យនោះទេ។ ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គទៅដល់ការធ្វើបណ្តឹងអាជ្ញានោះទេ ប្រសិនបើមានបទល្មើសណាមួយកើតឡើងនោះ។ បើសិនជាមានការទទួលទណ្ឌកម្មផ្នែកវិន័យរប់សព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាកំពុងតែជាប់នៅក្នុងនីតិវិធីវិន័យរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនោះ ព្រះរាជ-អាជ្ញារូបនោះនឹងត្រូវធ្វើការផ្អាកពីមុខងារជាបណ្តោះអាសន្ន ដែលធ្វើឡើងដោយក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ទណ្ឌកម្មខាងវិន័យត្រូវបានបែងចែកចេញជាពីរថ្នាក់៖

- **ថ្នាក់ទី ១ ( មួយ )**

- ការស្តីបន្ទោសដោយផ្ទាល់មាត់
- ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាជំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈពេលតែមិនត្រូវឲ្យលើសពី ២ ( ពីរ ) ឆ្នាំ ឬលុបឈ្មោះចេញពីតារាជំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែលព្រះរាជអាជ្ញារូបនោះមានឈ្មោះនៅក្នុងតារាងរួចមកហើយ។

- **ថ្នាក់ទី ២ ( ពីរ )**

- ការផ្លាស់ដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម
- ការព្យួរពីការងារមិនឲ្យមានបៀវត្ស ក្នុងរយៈពេលមិនលើសពី ១ ( មួយ ) ឆ្នាំ

- ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ
- ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ
- ការបញ្ឈប់ពីមុខងារដោយបង្ខំ
- ការបណ្តេញចេញពីក្របខណ្ឌ

ដើម្បីធ្វើទណ្ឌកម្មថ្នាក់ទី ២ ( ពីរ ) នេះ ត្រូវធ្វើដោយព្រះរាជក្រឹត្យ ដោយធ្វើការសម្រេចរួចមកហើយដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

បើក្នុងករណីព្រះរាជអាជ្ញារូមនោះ ត្រូវទទួលការបញ្ឈប់ពីមុខងារដោយបង្ខំ ឬការបណ្តេញចេញពីក្របខណ្ឌ ព្រះរាជអាជ្ញារូបនោះត្រូវមានសិទ្ធិក្នុងការទទួលបាននូវ ប្រាក់ទាំងអស់ ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួមមកហើយនោះ។

ព្រះរាជអាជ្ញាក៏ត្រូវលុបឈ្មោះចេញពីក្របខណ្ឌដូចគ្នាដែរ បើសិនជាព្រះរាជអាជ្ញារូបនោះបានបោះបង់ការងារចោល ឬអវត្តមានអស់រយៈពេលលើសពី ៣០ ( សាមសិប ) ថ្ងៃ ឬព្រះរាជអាជ្ញារូបនោះបានធ្វើការលាឈប់ពីការងាររបស់ខ្លួនដែលបាន ដាក់ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងបានចាត់ការតាមនីតិវិធីរួចហើយ។[17]

## ផ្នែកទី ៣៖ ការចោទប្រកាន់តាមផ្លូវតុលាការ

ក្នុងនាមជាព្រះរាជអាជ្ញាដែលមានអំណាចក្នុងការចោទប្រកាន់ ស៊ើបអង្កេតបឋម ឃាត់ខ្លួន បញ្ជូនខ្លួន និងអំណាចជាច្រើនដ៏ទៃទៀតដែលបានរៀបរាប់ដូចខាងលើមកនេះ ក៏ប៉ុន្តែក្នុងនាមជាព្រះរាជអាជ្ញា ត្រូវគោរពច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចនេះ ប្រសិនបើព្រះរាជអាជ្ញារូបណាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយនោះ គឺអាចនឹងត្រូវទទួលការចោទប្រកាន់ទៅតាមផ្លូវច្បាប់តុលាការនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចមានសិទ្ធិក្នុងការធ្វើការផ្ទេរសមត្ថកិច្ចទាក់ទងទៅលើរឿងព្រហ្មទណ្ឌដែលព្រះរាជអាជ្ញាបានប្រព្រឹត្តនោះ ឲ្យទៅសាលាដំបូងផ្សេងដែលមិនមែនជាសាលាដំបូងដែលព្រះរាជអាជ្ញារូបនោះស្ថិតនៅ ឬក៏កំពុងបំពេញមុខងារ។ កាលដែលធ្វើបែបនេះ គឺមានគោលបំណងក្នុងការបញ្ជាក់ទៅលើការកាត់ក្តីទៅលើបទល្មើសព្រហ្មទណ្ឌ

[17] មាត្រា ៨៩-៩៥, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ ២០១៤

របស់ព្រះរាជអាជ្ញារូបនោះដោយមានសុពលភាព និងសុចរិត និងដោយគ្មានការគាបសង្កត់។

បើក្នុងករណីព្រះរាជអាជ្ញារូបណាមួយបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌហើយ បើព្រះរាជអាជ្ញាផ្សេងទៀតបានដឹងនិងសម្រេចចោទប្រកាន់ ទៅលើព្រះរាជអាជ្ញារូបនោះ ព្រះរាជអាជ្ញាដែលដែលធ្វើការចោទប្រកាន់នោះ ត្រូវធ្វើសេចក្តីជូនដំណឹងទាក់ទងទៅនឹងការចោទប្រកាន់ជូនទៅ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឲ្យបានក្នុងរយៈពេលយ៉ាងយូរ ៧២ ម៉ោង។ តែបើក្នុងករណីត្រូវធ្វើការចាប់ខ្លួន ឬឃាត់ខ្លួនព្រះរាជអាជ្ញារូបណាមួយនោះ អាជ្ញាធរដែលមានសម្ថកិច្ចនោះ ត្រូវធ្វើការជូនដំណឹងទៅដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ទាក់ទងទៅនឹងការចាប់ខ្លួន ឬឃាត់ខ្លួនរបស់ព្រះរាជអាជ្ញានេះផងដែរ។

បន្ទាប់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានទទួលដំណឹងទាក់ទងទៅនិងបញ្ហារនេះហើយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវធ្វើការជូនដំណឹងនេះជាបន្ទាន់ទៅឲ្យ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

នៅក្នុងអំឡុងពេលសាលក្រមទៅលើរឿងក្តីព្រហ្មទណ្ឌរបស់ ព្រះរាជអាជ្ញារូបនោះកំពុងធ្វើការវិនិច្ឆ័យ ព្រះរាជអាជ្ញារូបនោះនិងត្រូវបានផ្អាកពីមុខងាររបស់ខ្លួនជាបណ្តោះអាសន្នមិនថាទាក់ទងទៅនឹងបមជ្ឈិម ឬក៏បទឧក្រិដ្ឋនោះទេ។ ការផ្អាកនេះនឹងត្រូវលុបចោលនៅពេលដែលសេចក្តីសម្រេច របស់តុលាកាអំពីទោសជាស្ថាពរបង្ហាញពីភាពគ្មានកំហុសរបស់ព្រះរាជអាជ្ញារូបនោះ។ នៅក្នុងអំឡុងពេលនៃការផ្អាកមុខងាររបស់ព្រះរាជអាជ្ញានេះ ព្រះរាជអាជ្ញារូបនោះ នៅមានសិទ្ធិក្នុងការទទួលបានប្រាក់បៀវត្សជាធម្មតារហូតដល់ពេលសាលក្រមរបស់តុលាការចេញថាមានទោស។ បើរសាលក្រមរបស់តុលាការដំបូងបានចេញថា ព្រះរាជអាជ្ញារូបនោះមានទោស ការទទួលប្រាក់បៀវត្សរបស់ព្រះរាជអាជ្ញារូបនោះនឹងត្រូវបានផ្អាកជាបណ្តោះអាសន្ន យោងទៅតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គិតចាប់ពីថ្ងៃដែលសាលក្រមរបស់តុលាការដំបូងបានចេញថាមានទោសពិតមែន។ ការផ្អាកនេះនៅតែបន្តទោះបីជាមានបណ្តឹងឧទ្ធរណ៍ទាក់ទងទៅនឹងសាលក្រមនោះក៏ដោយ។

តែនៅក្នុងករណីដែលសាលក្រមបានចេញមកថា ព្រះរាជអាជ្ញាជាប់ចោទតាមផ្លូវតុលាការនោះពុំមានទោស ទទួលបានការលើកលែងទោសចោទប្រកាន់ ឬ សម្រេចឲ្យរូបគាត់រួចផុតពីបទចោទប្រកាន់ជាស្ថាពរនោះ ព្រះរាជអាជ្ញារូបនោះនឹងទទួលបានការអនុញ្ញាតឲ្យចូលបម្រើការងារវិញភ្លាមៗ។ ហើយឋានន្តរស័ក្តិ សោធននិវត្តន៍ និងការទទួលប្រាក់បៀវត្សដែលត្រូវបានផ្អាកទាំងនោះនឹងត្រូវទទួលបានមកវិញទាំងអស់ ដោយគិតចាប់ពីអតីតកភាពថ្នាក់ និងឋានន្តរស័ក្តិ សោធននិវត្តន៍ និងប្រាក់បៀវត្សរបស់ព្រះរាជអាជ្ញារូបនោះ។ បើរក្នុងករណីដែលព្រះរាជអាជ្ញារូបនោះត្រូវបានលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញាទាក់ទងទៅនឹងការផ្តន្ទាទោសជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិមនោះ តែសាលក្រមបានចេញមកថាព្រះរាជអាជ្ញាជាប់ចោទតាមផ្លូវតុលាការនោះពុំមានទោស ទទួលបានការលើលែងទោស ឬសម្រេចឲ្យរួចផុតពីបទចោទប្រកាន់ជាស្ថាពរវិញនោះ ព្រះរាជអាជ្ញារូបនោះនិងត្រូវទទួលបានកិច្ចការងាររបស់ខ្លួនមកវិញដូចដែល ចំនុចខាងលើបានបង្ហាញផងដែរ។ ព្រះរាជអាជ្ញាជាប់ចោទតាមផ្លូវតុលាការអាចនឹងទទួលបានការលើកលែងការចោទប្រកាន់ ឬសម្រេចឲ្យរួចផុតពីបទចោទប្រកានពិតមែនប៉ុន្តែព្រះរាជអាជ្ញារូបនោះបានប្រព្រឹត្តខុសទៅលើក្រមសីលធម៌របស់ព្រះរាជអាជ្ញា នោះព្រះរាជអាជ្ញារូបនោះនៅតែទទួលការដាក់ឲ្យចោទប្រកាន់ជាប់វិន័យថែមទៀត ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

បើព្រះរាជអាជ្ញារូបនោះទទួលបានការផ្តន្ទាទោសទាក់ទងទៅនឹងបទមជ្ឈិម ឬបទឧក្រិដ្ឋដោយចេតនានោះ ព្រះរាជអាជ្ញារូបនោះនឹងត្រូវធ្វើការលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញាដែលគិតចាប់ពីថ្ងៃដែលសាលក្រម ឬសាលដីកានោះចូលជាស្ថាពរ។[18]

## ផ្នែកទី ៤៖ ការចូលនិវត្តន៍របស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាគ្រប់រូប និងភេទត្រូវចូលនិវត្តន៍ នៅពេលដែលខ្លួនមានអាយុគ្រប់ ៦០ (ហុកសិប) ឆ្នាំ។ តែ ក្នុងករណីព្រះរាជអាជ្ញាទាំងអស់នៃមហាអយ្យការអមតុលាការកំពូលមានអាយុលើសពី ៦០ (ហុកសិប) ឆ្នាំឡើងទៅ ត្រូវធ្វើការចូលនិវត្តន៍ដោយការស្នើសុំដោយសាមីខ្លួនផងដែរ។ តែដល់ពេលអាយុ ៦៥ (ហុកសិបប្រាំ) ឆ្នាំហើយមិនទាន់បានចូលនិវត្តន៍នោះទេ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនិងត្រូវសម្រេចពីការបន្ត ឬក៏ដាក់ឲ្យ

[18] មាត្រា ១០០, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ ២០១៤

ចូលនិវត្តន៍នៃព្រះរាជអាជ្ញារូបនោះដោយសាមីខ្លួនផងដែរ ហើយដើម្បីធ្វើការដាក់ឲ្យចូលនិវត្តន៍នេះទៅបាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវលើកសេក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រទាក់ទងទៅនឹងបញ្ហាខាងលើនេះ។

ព្រះរាជអាជ្ញាអាចសុំចូលនិវត្តន៍មុនអាយុ ៦០ឆ្នាំបាននៅក្នុងករណីដែលព្រះរាជអាជ្ញារូបនោះបានបម្រើការងារអស់រយៈពេលគ្រប់ ៣០ ( សាមសិប ) ឆ្នាំរួចមកហើយ។ ហើយព្រះរាជអាជ្ញាដែលបានបម្រើការងារអស់រយៈពេលគ្រប់ ៣០ ( សាមសិប ) ឆ្នាំនោះក៏មានសិទ្ធិក្នុងការទទួលបានប្រាក់សោធននិវត្តន៍អតិតភាព នៃប្រាក់បៀវត្សចុងក្រោយ របស់ខ្លួនផងដែរ។ តែក្នុងករណីដែលព្រះរាជអាជ្ញារូបនោះបានបម្រើការងារអស់រយៈ ពេល លើសពី ២០ ( ម្ភៃ ) ឆ្នាំ ទៅក្រោម ៣០ ( សាមសិប ) ឆ្នាំ ព្រះរាជអាជ្ញារូបនោះនឹងមានសិទ្ធិក្នុងការទទួលបានប្រាក់សោធននិវត្តន៍សមាមាត្រ នៃប្រាក់បៀវត្សចុងក្រោយរបស់ខ្លួន។ ក្នុងករណីដែលព្រះរាជអាជ្ញារូបនោះបានបម្រើការងារក្រោមរយៈពេល ២០ ( ម្ភៃ ) ឆ្នាំ ព្រះរាជអាជ្ញារូបនោះមានសិទ្ធិក្នុងការទទួលបានប្រាក់សោធននិវត្តន៍ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗ ទៀតតែមួយលើកប៉ុណ្ណោះ។ ការគិតរយៈពេលនៃការបម្រើការងារនេះត្រូវគិតចាប់តាំងពី ពេលដែលព្រះរាជអាជ្ញារូបនោះបានបម្រើការងារជាអ្នករាជការសាធារណៈ មុនពេលដែលទទួលបានឋានន្តរស័ក្តិ ឬការតែងតាំងជាព្រះរាជអាជ្ញា។ ទីកន្លែងក្នុងការបើកប្រាក់សោធននិវត្តន៍របស់ព្រះរាជអាជ្ញានេះ ស្ថិតនៅអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលប្រាក់សោធននិវត្តន៍នេះអាចបើកបាននៅតែមួយកន្លែងនេះគត់ ហើយការអនុវត្តរបបសោធននិវត្តន៍នេះត្រូវធ្វើការកំណត់យ៉ាងលំអិតដោយអនុក្រឹត្យ។

ការកាត់ប្រាក់សោធននិវត្តន៍មិនត្រូវធ្វើការបន្តរកាត់ទៀតនោះទេ ប្រសិនបើព្រះរាជអាជ្ញារូបនោះមានអតីតភាពការងារគ្រប់ ៣០ ( សាមសិប ) ឆ្នាំហើយនោះ។ ដោយការកាត់ប្រាក់សោធននិវត្តន៍អតីតភាពនេះនឹងត្រូវធ្វើការកាត់លុះត្រាតែ ព្រះរាជអាជ្ញារូបនោះពុំទាន់បានបម្រើការងារគ្រប់ ៣០ ( សាមសិប ) ឆ្នាំនៅឡើយ។ ដូចនេះការកាត់ប្រាក់សោធន-និវត្តន៍នេះនិងធ្វើការបន្តកាត់រហូតដល់ពេល ដែលព្រះរាជអាជ្ញារូបនោះបានបម្រើការងារគ្រប់រយៈពេល ៣០ ( សាមសិប ) ឆ្នាំ ដែលអតិតភាពការងារត្រូវគិតចាប់ពីថ្ងៃដែលសាមីខ្លួននោះបានចូលបម្រើការងាររដ្ឋទោះនៅក្នុងសម័យណាក៏ដោយ។

ការដាក់ឲ្យចូលនិវត្តន៍របស់ព្រះរាជអាជ្ញាអាចនឹងប្រព្រឹត្តទៅបាន ដែលនៅក្នុងករណីដែលព្រះរាជអាជ្ញារូបណាមួយ មិនអាចធ្វើការបំពេញការងារបានក្នុងវិជ្ជាជីវៈរបស់ខ្លួន ដោយមូលហេតុបាត់បង់សម្បទាវិជ្ជាជីវៈ។ ការសម្រេចនេះនឹងត្រូវធ្វើទៅដោយ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តែត្រូវយោងទៅលើលិខិតកោសលវិច័យសំអាងមួយដែលចេញដោយពេទ្យជំនាញដែលត្រូវបានចាត់តាំងឲ្យដោយក្រសួងសុខាភិបាល។ ព្រះរាជអាជ្ញារូបនោះនឹងត្រូវដាក់ឲ្យ ចូលនិវត្តន៍ដោយមានសិទ្ធិពិសេសទទួលបានប្រាក់សោធននិវត្តន៍សម្រាប់ទុព្វលភាពដែលមានចំនួនស្មើនឹងសោធននិវ្តន៍អតីតភាព ដោយមិនគិតពិរយៈពេលបម្រើការងារនោះទេ នៅក្នុងករណីការបាត់បង់សម្បទាវិជ្ជាជីវៈនោះបណ្តាលមកពី៖

- ការបំពេញការងាររបស់ខ្លួន
- មនសិការខិតខំខ្លាំងទៅលើកិច្ចការដែលមានប្រយោជន៍ដល់សាធារណៈ ។
- ជំងឺ ឬពិការភាពនោះ ជាមូលហេតុផ្ទាល់ ហើយច្បាស់លាស់នៃទុព្វលភាព ឬអសមត្ថភាពបំពេញការងារ។

មូលហេតុ ប្រភព ប្រភេទ និងស្លាកស្នាមនៃរបួស ឬជំងឺរបស់ព្រះរាជអាជ្ញាត្រូវមានបញ្ជាក់ដោយលិខិតកោសល្យវិច័យរបស់ពេទ្យជំនាញដែលបានចាត់តែងដោយក្រសួងសុខាភិបាល។

នៅក្នុងករណីដែលព្រះរាជអាជ្ញាទទួលមរណភាពដោយសារ ការបម្រើការងារយ៉ាងស្វិតស្វាញរបស់ខ្លួននោះ សហព័ទ្ធ និងកូនដែលស្ថិតនៅជាអនីតិជននោះ អាចត្រូវទទួលបានប្រាក់បំណាច់ស្មើនឹង ប្រាក់បៀវត្សរបស់ព្រះរាជអាជ្ញាដែលបានទទួលមរណភាពនោះចំនួន ១២ ( ដប់ពីរ ) ហើយមិនតែប៉ុណ្ណោះ រដ្ឋនឹងត្រូវធ្វើការឧបត្ថម្ភកូនដែលស្ថិតនៅជាអនីតិជននោះ និងសហព័ទ្ធរបស់ព្រះរាជអាជ្ញាដែលបានទទួលមរណភាពនោះ។ ប៉ុន្តែការឧបត្ថម្ភនោះនិងត្រូវបានកាត់ផ្តាច់លុះត្រាតែ សហព័ទ្ធរបស់ព្រះរាជអាជ្ញាដែលបានទទួលមរណភាពនោះបានរៀបអាពាហ៍ពិពាហ៍សាជាថ្មី។

បើសិនមានការបាត់បង់កាយសម្បទាវិជ្ជាជីវៈ ដូចដែលបានបង្ហាញខាងលើនេះពិតមែនវាជាតួនាទីរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងការធ្វើរបាយការណ៍ ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីធ្វើការពិនិត្យមើល ហើយនិងធ្វើការសម្រេចចិត្តទាក់ទងទៅនឹងបញ្ហារនេះ

ថានឹងដាក់ឲ្យចូលនិវត្តន៍ដែរឬទេ។ ចំណែកឯរដ្ឋមន្ត្រីក្រសួងយុត្តិធម៌វិញ ត្រូវលើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយទៅដល់ព្រះមហាក្សត្រដើម្បីធ្វើការសម្រេច បន្ទាប់ពីបានទទួលការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការអាន និងស្វែងយល់អំពីអង្គការអយ្យការរួចមកហើយនោះ យើងបាន យល់ដឹងបន្ថែម អំពីចំណុចជាច្រើនដែលមានសារៈសំខាន់ជាខ្លាំងនៅក្នុងផ្នែកនីតិសាស្ត្រ ហើយ យើងបានដឹងថាអង្គការអយ្យការនេះ ត្រូវបានដើរតួរយ៉ាងសំខាន់ផងដែរនៅក្នុង សង្គមកម្ពុជានាពេលបច្ចុប្បន្ន។

យើងបានធ្វើការសិក្សាទៅលើការ បែងចែកឋានានុក្រមនៃអង្គការអយ្យការដែលមាន នៅអមសាលាកំពូល ឧទ្ធរណ៍ និងដំបូងនៃព្រះរាជាណាចក្រកម្ពុជាយើង ដែលត្រូវបានបែង ចែកចេញជាច្រើនដំណាក់កាលទៀត។ យើងក៏បានធ្វើការសិក្សាទៅលើគោលការណ៍របស់ អង្គការអយ្យការដែលមានតួនាទី ក្នុងការមើលខុសត្រូវទៅលើបញ្ហាដែលស្ថិតនៅក្រោមការ ត្រួតពិនិត្យរបស់ខ្លួនផងដែរ។ ការជ្រើសរើសព្រះរាជាអាជ្ញាគឺជាចំណុចដ៏សំខាន់មួយដែល ជួយអោយសិស្សនិស្សិតផ្នែកនីតិសាស្ត្រ ឬបេក្ខជន បេក្ខនារីផ្សេងៗទៀតដែលមានទំរង់ ស្របទៅតាមលក្ខខណ្ឌ នៅក្នុងការជ្រើសរើសព្រះរាជអាជ្ញានេះ ក្នុងការត្រៀមខ្លួនទៅថ្ងៃ អនាគតផងដែរ។ បន្ទាប់ពីនេះទៀត យើងបានសិស្សាអំពីដំណាក់កាលផ្សេងៗទៀតបន្ទាប់ ពីប្រឡងជាប់ជាព្រះរាជអាជ្ញាកម្មសិក្សា ដែលត្រូវចុះកម្មសិស្សារយៈពេល១ឆ្នាំនោះផងដែ រ។ យើងបានធ្វើការពិគ្រោះអំពីអង្គការអយ្យការនិង អំណាចរបស់ព្រះរាជអាជ្ញានៅក្នុង សាលាដំបូងដែលមានជាច្រើនដូចជា អំណាចក្នុងការធ្វើបណ្ដឹងអាជ្ញា ក្នុងការស៊ើបអង្កេ តផ្ទាល់ ការតម្កល់រឿងទុកឥតចាត់ការ និងអំណាចផ្សេងៗជាច្រើនទៀតដែលមានសារៈ សំខាន់បំផុតសម្រាប់ទទួលការយល់ដឹង ជាពិសេសនោះ សិស្សនិស្សិតដែលមានបំណង ក្នុងថ្ងៃអនាគតដើម្បីក្លាយទៅជាព្រះរាជអាជ្ញាមួយរូបនោះផងដែរ។ យើងក៏បានសិក្សាអំពី អំណាចរបស់ព្រះរាជអាជ្ញានៅសាលាឧទ្ធរណ៍ និងកំពូលរួចមកហើយដែរ។ ពីនេះទៅទៀត យើងបានសិក្សាអំពីការដំឡើងថ្នាក់របស់ព្រះរាជអាជ្ញា ដែលមានលក្ខខណ្ឌមួយចំនួនដើម្បី ព្រះរាជអាជ្ញាគ្រប់រូបត្រូវបំពេញក្នុងការទទួលបានការដំឡើងថ្នាក់នេះ។ ការតែងតាំង ផ្លាស់ ប្តូរ ពីមុខងារ ក៏បានធ្វើការបង្ហាញផងដែរនៅក្នុងសារណានេះ។ ជាពិសេសនោះការលុប ឈ្មោះរបស់ព្រះរាជអាជ្ញា។ ជាចុងក្រោយនោះគឺការចូលនិវត្តន៍របស់ព្រះរាជអាជ្ញា។

បន្ទាប់ពីបានធ្វើការស្រាវជ្រាវអស់រយៈពេលជាយូរទៅលើប្រធានបទទាក់ទងនឹង អង្គការអយ្យការមួយនេះ ពួកយើងទាំងពីរនាក់ពិតជាមានអារម្មណ៍រំភើប និងត្រេកអរដែលពួកយើងទាំងពីរនាក់បានជ្រើសរើសយកប្រធានបទមួយនេះ ពីព្រោះប្រធានបទនេះបានបង្ហាត់បង្រៀនយើងទាំងពីអ្នកឲ្យយល់ពីអង្គការអយ្យការ និងអំណាចរបស់ព្រះរាជអាជ្ញាគ្រប់ជាន់ថ្នាក់។ សម្រាប់ខ្លួនជានិសិត្សផ្នែកនីតិសាស្ត្រ ពួកយើងពិតជាសប្បារីករាយណាស់ដែលបានស្វែងយល់ពីប្រធានបទមួយនេះ ហើយពួកយើងសង្ឃឹមថាសារណាបញ្ចប់ការសិស្សាមួយនេះនិងអាចជួយសិស្ស និស្សិតជំនាន់ក្រោយអោយធ្វើការស្វែងយល់ ពីប្រធានបទមួយនេះដោយមានភាពងាយស្រួល។

# ឯកសារយោង

## ១. កម្រងឯកសារច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៦
- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧
- ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ ២០១៤

## ២. កម្រងឯកសារសៀវភៅ

- អានសូរីដា សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌ នៅកម្ពុជាបច្ចុប្បន្ន
- សូរីដា ,បោះពុម្ពលើកទី១ .ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន .ឆ្នាំ ២០១១